**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិកាន់កាប់ដីនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **អេល ភូប**
**ស៊ឹម គីម៉ី**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២

ឆ្នាំចូលរៀន ២០១៥
ឆ្នាំសរសេរសារណា ២០១៩

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **អេល ភួប** និង **ស៊ឹប គីម៉ី** ជានិស្សិតថ្នាក់រដ្ឋបាលសាធារណៈជំនាន់ទី១២នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ចសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅ ជូនចំពោះ។

លោកឪពុក និង អ្នកម្តាយ ដែលបានផ្តល់ជីវិតដ៏មានតម្លៃ ផ្តល់មេត្តា ករុណា និងការផ្គត់ផ្គង់ ដ៏ធំធេង ដល់យើងខ្ញុំសម្រាប់ការរស់នៅថ្លៃថ្នូរ និងការសិក្សា។

លោកសាស្ត្រាចារ្យ **បណ្ឌិត ហាប់ ផល្លី** ជានាយកគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រសេដ្ឋកិច្ចដែលបានចំណាយពេលវេលាដ៏មាន តម្លៃក្នុងការពិនិត្យវាយតម្លៃជួយណែនាំ ដល់យើងខ្ញុំក្នុងការសរសេរបញ្ចាប់សារណា ការចុះស្រាវជ្រាវ និងការពារប្រកបដោយខ្លឹមសារល្អ។

លោកសាស្ត្រាចារ្យ បណ្ឌិត លោក លោកស្រីសាស្ត្រាចារ្យ គ្រូបង្រៀន គ្រប់មុខវិជ្ជាដែល បានផ្តល់ចំណេះដឹង ពុទ្ធិ គំនិតយោបល់ល្អៗ ដល់រូបយើងខ្ញុំក្នុងការសិក្សាតាំងពីឆ្នាំមូលដ្ឋានរហូត ដល់ឆ្នាំទី៤ ព្រមទាំងមិត្តភក្តិទាំងអស់ដែលបានជួយគាំទ្រនិងលើកទឹកចិត្តដល់រូបយើងខ្ញុំ។

ជាទីបញ្ចាប់យើងខ្ញុំសូម ប្រសិទ្ធិពរជ័យ សេរីបវរ មហាប្រសើរ ឧត្តុង្គឧត្តម គោរពជូនដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បណ្ឌិត និងមិត្តភក្តិទាំងអស់ ឲ្យជួបតែសេចក្តីសុខ សុខភាពល្អ និង ជួបប្រទះតែសំណាងល្អគ្រប់ពេលវេលា គ្រប់ទីកន្លែង។

## **អារម្ភកថា**

របបកម្មសិទ្ធិនៅប្រទេសកម្ពុជា បានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៩៩២បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានដួលរលំ។ ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអចលនវត្ថុរបស់ខ្លួនដោយស្ថិតនៅក្រោមច្បាប់បានចែង និងរួមចំណែកក្នុងការកាត់បន្ថយវិវាទដីធ្លីនៅប្រទេសកម្ពុជា។ ហេតុដូចនេះយើងខ្ញុំសម្រេចចិត្តលើកយកប្រធាន«**សិទ្ធិកាន់កាប់ដីនៅកម្ពុជា** » នៅក្នុងសារណាបញ្ចាប់ថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ។ ដើម្បីរួមចំណែកជាដើមទុនសម្រាប់ការស្រាវជ្រាវនិងឈ្វេងយល់ដល់ប្រជាពលរដ្ឋខ្មែរ ជាពិសេសមិត្តៗនិស្សិត។

សារណាដែលនិយាយពី« **សិទ្ធិកាន់កាប់ដីនៅកម្ពុជា** » នេះពន្យល់និងវែកញែកពីរបៀបនៃសិទ្ធិទទួលបានការកាន់កាប់ដីធ្លីនៅក្នុងប្រទេសកម្ពុជា និងបង្ហាញពីកម្មសិទ្ធិករនិងភោគៈជាដើម។ ការជជែកពិភាក្សាលើបុគ្គលដែលមានសិទ្ធិកាន់កាប់ដីធ្លី ដើម្បីឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់ដើម្បីជាបច្ច័យក្នុងការជួយកាត់បន្ថយបញ្ហាដីធ្លីនៅកម្ពុជា។

កម្រងអត្ថបទសារណានេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ជាសៀវភៅមួយដែលអាចចូលរួមចំណែកក្នុងការបណ្តុះគំនិតប្រជាពលរដ្ឋឲ្យកាន់តែយល់ច្បាស់បន្ថែមពីសិទ្ធិទទួលបានដីយកមកកាន់កាប់ដោយស្របតាមនីត្យានុកូលភាព នៃព្រះរាជាណាចក្រកម្ពុជា។

អត្ថបទសារណានេះ បើសិនមានកន្លែងកង្វះខាតត្រង់ចំណុចណាមួយយើងខ្ញុំ រីករាយទទួលយកការ រិះគន់កែតម្រូវក្នុងន័យស្ថាបណាពីសំណាក់ ឯកឧត្តម អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអាន ដោយក្តីសោមនស្សរីករាយ។

ថ្ងៃចន្ទ ១៣កើត ខែផល្គុនឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# មាតិកា


**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**សេចក្តីផ្តើម** ........................................ ១

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........................................ ១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........................................ ១

**៣. គោលបំណងនៃការស្រាវជ្រាវ** ........................................ ២

**៤. គោលគំនិតនៃការស្រាវជ្រាវ** ........................................ ២

**៥. ដែនកំណត់ និងវិសាលភាពនៃស្រាវជ្រាវ** ........................................ ២

**៦. សារៈសំខាន់ នៃការស្រាវជ្រាវ** ........................................ ២

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........................................ ៣

**ជំពូកទី១**

**ប្រវត្តិនៃសិទ្ធិកាន់កាប់**

**១.១.សញ្ញាណទូទៅនៃសិទ្ធិកាន់កាប់** ........................................ ៤

**១.១.១.ប្រវត្តិនៃសិទ្ធិកាន់កាប់** ........................................ ៤

១.១.១.១.ខ្មែរសម័យមុនអាណានិគមរបស់បារាំង........................................៤

១.១.១.២. សម័យក្រោមអាណានិគមរបស់បារាំង........................................៥

១.១.១.៣. កម្ពុជាសម័យឯករាជ្យ........................................៧

១.១.១.៤.កម្ពុជាប្រជាធិបតេយ្យ........................................៧

១.១.១.៥.របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា........................................ ៧

១.១.១.៦.សម័យរដ្ឋកម្ពុជា........................................៨

១.១.១.៧.ព្រះរាជាណាចក្រកម្ពុជា........................................១០

**១.១.២.និយមន័យ នៃសិទ្ធិកាន់កាប់** ........................................ ១០

១.១.៣.ប្រភព នៃសិទ្ធិកាន់កាប់ ........ ១១

១.១.៤. រចនាសម្ព័ន្ធនៃសិទ្ធិកាន់កាប់ ........ ១២

## ជំពូកទី២

## កំណើនប្រជាពលរដ្ឋបាត់បង់សិទ្ធិកាន់កាប់ដីធ្លី

២.១. ការកាន់កាប់ដីធ្លីគ្មានប័ណ្ណកម្មសិទ្ធិ ........ ១៤

២.១.១. ការកាន់កាប់ដីធ្លីមុនច្បាប់ភូមិបាលឆ្នាំ២00១ ចូលជាធរមាន ........ ១៤

២.១.២. ការកាន់កាប់ដីធ្លីក្រោយច្បាប់ភូមិបាលឆ្នាំ២00១ចូលជាធរមាន ........ ១៥

២.២. បញ្ហាវិវាទដីធ្លី ........ ១៦

២.២.១. ប្រភេទនៃករណីវិវាទដីធ្លី ........ ១៨

២.២.២. ដីធ្លីមិនទាន់បានចុះបញ្ជី ........ ១៩

២.២.៣. ការចូលកាន់កាន់ដីមិនស្របច្បាប់ ........ ២១

២.២.៤. ការផ្តល់សម្បទានដីសេដ្ឋកិច្ច ........ ២២

## ជំពូកទី៣

## យន្តការដោះស្រាយ

៣.១. នីតិវិធីទទួលបានប័ណ្ណកម្មសិទ្ធិ ........ ២៨

៣.២.ការចុះបញ្ជីដីធ្លី ........ ៣១

៣.២.១.ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ........ ៣២

៣.២.២.កាចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ........ ៣៤

៣.២.៣.ការចុះបញ្ជីដីបំពេញបន្ថែម ........ ៣៦

**សេចក្តីសន្និដ្ឋាន** ........ ៣៨

**អនុសាសន៍** ........ ៤០

**ឯកសារយោង**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

សិទ្ធិកាន់កាប់ដីធ្លី គឺជាប្រធានបទមួយដែលមានសារៈសំខាន់ ក្នុងការជជែកពិភាក្សាអំពីបញ្ហាដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ពឹងផ្អែកដីធ្លីជារបរចិញ្ចឹមជីវិតរបស់ពួកគេ។ បន្ទាប់ពីប្រទេសកម្ពុជាបានអនុញ្ញាតឲ្យមានរបបកម្មសិទ្ធិ ដោយមានការបង្កើតច្បាប់ក្នុងការ ការពារប្រយោជន៍ជូនប្រជាពលរដ្ឋ ក្នុងការកាន់កាប់ដោយស្របច្បាប់។

ប៉ុន្តែទន្ទឹមនឹងនេះ គេបានសង្កេតឃើញថាបញ្ហាដីធ្លីបានកើនមានឡើងជាបន្តបន្ទាប់។ ដែលជាបន្ទុករបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហានេះប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល និងមានកិច្ចសហការចូលរួមពីសំណាក់អ្នកដែលពាក់ព័ន្ធ។ ម្យ៉ាងវិញទៀតការកាន់កាប់ដីធ្លីមិនស្របតាមបទដ្ឋានគតិយុត្តិ ជាធាតុផ្សំមួយបង្កឲ្យមានបញ្ហាដីធ្លីឡើងវិញ មិនចេះចប់មិនចេះហើយ។

ការកាន់កាប់ដីធ្លីដែលមិនស្របទៅតាមនីត្យានុកូលភាព។ ប្រជាពលរដ្ឋកម្ពុជាមិនទាន់បានយល់ឲ្យស៊ីជម្រៅនៅឡើយទាក់ទង ការទទួលបានសិទ្ធិកាន់កាប់ដីដែលស្របច្បាប់។ ដែលជាមូលហេតុមួយបង្កឲ្យមានបញ្ហាវិវាទដីធ្លីកើតឡើងជារឿយៗ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សានេះ ផ្អែកទៅលើមូលដ្ឋាននៃបទដ្ឋានគតិយុត្តិ ដោយមានច្បាប់ភូមិបាលនិងក្រមរដ្ឋប្បវេណី អនុក្រឹត្យ និងព្រះរាជក្រឹត្យ និងច្បាប់ជាច្រើនទៀតដែលពាក់ព័ន្ធបញ្ហានេះ។ អ្វីដែលពិសេសនោះបញ្ហាដែលកើតឡើងទាក់ទិន និងសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជា។

ដើម្បីសម្រេចបាននូវគោលបំណង យើងបានដាក់ចេញនូវសំណួរស្រាវជ្រាវលើបញ្ហានៃសិទ្ធិកាន់កាប់ដីធ្លីនេះ។

តើប្រជាពលរដ្ឋកម្ពុជា ទទួលបានសិទ្ធិកាន់កាប់ដីធ្លី ដោយរបៀបណាឬតាមនីតិវិធីយ៉ាង ដូចម្តេច?

តើប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិអ្វីខ្លះក្នុងការគ្រប់គ្រងទៅលើដីធ្លី ?

### ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីរួមចំណែកកាត់បន្ថយបញ្ហាដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះ ធ្វើការឈ្វេងយល់ពីចំណុចអវិជ្ជមាន ដែលកើតមាននៅជុំវិញវិធីសាស្ត្រក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លី ដើម្បីធ្វើការកែលម្អ។ គោលបំណងនៃការស្រាវជ្រាវ គឺសិក្សាឈ្វេងយល់នៅចំណុចមួយចំនួន។ សិក្សាឈ្វេងយល់ពីស្ថានភាពកាន់កាប់ដីធ្លីមុនពេលច្បាប់ភូមិចូលជាធរមាន និងឈ្វេងយល់ស្ថានភាពកាន់កាប់ដីធ្លីបន្ទាប់ពីច្បាប់ភូមិបាលចូលជាធរមាន។ មិនតែប៉ុណ្ណោះ និងសិក្សាពីនីតិវិធីនៃសិទ្ធិទទួលបានការកាន់កាប់ដីធ្លីនៅកម្ពុជា។

### ៤. គោលគំនិតនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ឈ្វេងពីស្ថានភាពប្រភេទដីធ្លីដែលប្រជាពលរដ្ឋមានសិទ្ធិអាចកាន់កាប់បាន និងលក្ខខណ្ឌដែលនាំឲ្យទទួលបានសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជា។

### ៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

សារណានេះគ្រប់ដណ្តប់លើសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ន។ ការសិក្សានេះបានផ្តោះទៅលើនីតិវិធីច្បាប់ភូមិបាល និងក្រមរដ្ឋប្បវេណីនៅកម្ពុជា។ ទន្ទឹមនិងនេះ ដើម្បីសិក្សាពីប្រសិទ្ធិភាពក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជា។

### ៦. សារៈសំខាន់ នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ និងផ្តល់សារៈសំខាន់ដល់សង្គមជាតិ ដល់អ្នកស្រាវជ្រាវនិងខ្លួនឯងស្រាវជ្រាវ។ សារៈសំខាន់ចំពោះសង្គមជាតិ គឺការកាត់បន្ថយបញ្ហាដីធ្លីតាមទីប្រជុំជន និងការអនុវត្តនីតិវិធីនៃសិទ្ធិទទួលបានការកាន់កាប់ដីធ្លី។ ប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ដីធ្លីដោយស្របច្បាប់។ ចំពោះអ្នកស្រាវជ្រាវជាឯកសារក្នុងការជួយបំភ្លឺបន្ថែមដល់អ្នកស្រាវជ្រាវជំនាន់ក្រោយ យកទៅសិក្សាស្រាវជ្រាវបន្ត។

ជារួមសារណានេះ និងជួយជាដើមទុនដែលធ្វើឲ្យយើងកាន់តែយល់បានស៊ីជម្រៅទាក់ទងទៅ និងសិទ្ធិកាន់កាប់ដីធ្លី។ មែនទែនទៅសារណាបញ្ចាប់ការសិក្សាមួយនេះ និងអាចរួមចំណែកក្នុងការអនុវត្តគំនិត និងស្មារតីទៅដល់ប្រជាពលរដ្ឋខ្មែរ ជាពិសេសមិត្តអ្នកអានទាំងអស់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះចែកចេញជា៣ជំពូក។ ជំពូកទី១បង្ហាញពីប្រវត្តិនៃសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជាតាំងពីមុនសម័យអាណានិគមបារាំង រហូតមកដល់បច្ចុប្បន្ន។ ជំពូកទី២ពិភាក្សាអំពីមូលហេតុដែលនាំឲ្យមានកំណើនប្រជាពលរដ្ឋបាត់បង់នូវសិទ្ធិកាន់កាប់ដីធ្លី។ ជំពូកទី៣បកស្រាយពីដំណោះស្រាយដែលធ្វើឲ្យប្រជាពលរដ្ឋបាត់បង់នូវសិទ្ធិកាន់កាប់ដីធ្លីនៅកម្ពុជា។

# ជំពូកទី១

# ប្រវត្តិនៃសិទ្ធិកាន់កាប់

## ១.១.សញ្ញាណទូទៅនៃសិទ្ធិកាន់កាប់

### ១.១.១.ប្រវត្តិនៃសិទ្ធិកាន់កាប់

សញ្ញាណនៃសិទ្ធិកាន់កាប់ដីនៅកម្ពុជា មានជាយូរណាស់មកហើយ និងមានការប្រែប្រួលទៅតាមសម័យកាលនីមួយៗ។ ដែលសម័យកាលនីមួយៗនោះបានបង្ហាញពីសិទ្ធិលើការកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ។

#### ១.១.១.១.ខ្មែរសម័យមុនអាណានិគមរបស់បារាំង

អនុលោមទៅតាមច្បាប់របស់ខ្មែរពីសម័យមុនព្រះមហាក្សត្រ គឺម្ចាស់នៃដីទាំងអស់នៅរដ្ឋកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ សិទ្ធិភោគៈរបស់ប្រជារាស្ត្រលើដីធ្លីត្រូវបានទទួលស្គាល់ និងការពារ។ ក្នុងអំឡុងពេលនោះ សង្គមខ្មែរត្រូវបានបែងចែកជាវណ្ណៈផ្សេងៗគ្នា ក្រៅពីញាតិវង្សានុវង្សគឺមានវណ្ណៈសង្គមផ្សេងៗទៀត រួមមាន ក្សត្រា(អ្នកចម្បាំង) សមាជិកនៃក្រុមសាសនាផ្សេងៗ(ព្រហ្មសាសនា ព្រះពុទ្ធសាសនា សាសនាតៅ) អ្នកដែលមានសេរីភាព និងទាសាទាសី។ ការបែងចែក វណ្ណៈក្នុងសង្គមបានធ្វើឲ្យប្រជាពលរដ្ឋមានសិទ្ធិខុសគ្នាអាស្រ័យទៅតាមវណ្ណៈរបស់ខ្លួន។ ដូច្នេះនៅពេលនិយាយសំដៅដល់សិទ្ធិរបស់បុគ្គលក្នុងការកាន់កាប់ដីធ្លី យើងមិនអាចសន្និដ្ឋានបានថាបុគ្គលគ្រប់រូបអាចមានសិទ្ធិដូចគ្នានោះទេ។ សិទ្ធិនៃការកាន់កាប់ដីធ្លី អាចមានចំពោះតែសមាជិកវណ្ណៈមួយចំនួនក្នុងសង្គមតែប៉ុណ្ណោះ។ ប៉ុន្តែសម្រាប់ប្រជាជនដែលបានអាស្រ័យផលលើសិទ្ធិជាភោគៈ សិទ្ធិនោះត្រូវបានទទួលស្គាល់នៅពេលដែលដីនោះត្រូវបានទទួលនៅពេលដែលដីនោះត្រូវបានបង្កើនផល(រួមមានការរុនរានសង់ផ្ទះឬធ្វើរបង)ដោយគ្មានការអាក់ខាននិងមានការដឹងឮជាសាធារណៈ។ នៅពេលដែលប្រជាជនទទួលបានសិទ្ធិលើភោគៈលើដីហើយ សិទ្ធិភោគៈនោះ អាចផ្ទេរបានតាមរយៈសន្តិកម្ម ឬ មរតកសាសន៍ ហើយក៏អាចជាកម្មវត្ថុដែរ នៅពេលដែលដីនោះត្រូវបានបោះបង់ចោលក្នុងរយៈពេល៣ឆ្នាំ។ ក្នុងករណីនេះ សិទ្ធិរបស់អ្នកកាន់កាប់ថ្មីត្រូវបានទទួលស្គាល់

ហើយភោគីដើម មិនមានសិទ្ធិទាមទារយកដីនោះមកវិញបានទេ។ ចំពោះប្រជាជនដែលមានសិទ្ធិភោគ:លើដីដែលបានទទួលស្គាល់ ជនម្នាក់ៗមិនចាំបាច់ដាក់ពាក្យ ឬធ្វើសេចក្តីប្រកាសទៅអាជ្ញាធរមូលដ្ឋានទេ។ ប៉ុន្តែត្រូវធ្វើសេចក្តីប្រកាសសម្រាប់ជាគោលបំណងនៃការបង់ពន្ធថ្វាយព្រះមហាក្សត្រ។ តាមច្បាប់ខ្មែរសម័យមុន មិនមានការបង់ពន្ធលើដីធ្លីដូចសម័យបច្ចុប្បន្ននេះទេ។ ផ្ទុយទៅវិញ ពន្ធក្នុងទម្រង់ជាសួយសាអាករត្រូវបង់ទៅលើភោគផលដំណាំដែលប្រមូលបានក្នុងឆ្នាំនីមួយៗ។ របបពន្ធដារគេយមិនគិតទៅលើដីទេ តែគិតតាមភោគផលដំណាំ គឺតាមសកម្មភាព បង្កបង្កើនផលកសិកម្ម។ របបពន្ធដារអំឡុងពេលប្រមូលភោគផល«អាជ្ញាហ្លួង»ឬមន្ត្រីរាជវាំងចុះទៅតាមខេត្តនានា។ ក្នុងភូមិនីមួយៗគេត្រូវប្រគល់បញ្ជីឈ្មោះរបស់កសិករនិងពាណិជ្ជកម្មជូនទៅឲ្យអាជ្ញាហ្លួង ឬមន្ត្រីរាជវាំងទាំងនោះ។ តាមរយៈពេលនៃការប្រើប្រាស់បញ្ជីឈ្មោះទាំងនេះ អាជ្ញាហ្លួង វាយតម្លៃភោគផលដំណាំនៅកន្លែងរបស់កសិករហើយកត់ត្រាចូលក្នុងសៀវភៅពន្ធដាដែលកសិករបានជំពាក់។ សរុបមក តាមច្បាប់ខ្មែរសម័យមុនប្រជាជនធ្វើសេចក្តីប្រកាសទៅអាជ្ញាធរ ជាការចាំបាច់សម្រាប់គោលបំណងនៃការប្រមូលពន្ធឲ្យរដ្ឋ ប៉ុន្តែមិនតម្រូវឲ្យធ្វើសម្រាប់ការទទួលស្គាល់សិទ្ធិរបស់ភោគីលើដីនោះទេ។[1]

**១.១.១.២. សម័យក្រោមអាណានិគមរបស់បារាំង**

អនុសញ្ញាឆ្នាំ១៨៨៤ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសបារាំងបានផ្ទេរឬប្រគល់អំណាចផ្នែករដ្ឋបាលរបស់រដ្ឋឲ្យទៅបារាំង។ ព្រះមហាក្សត្រស៊ីសុវត្ថិដែលឡើងគ្រងរាជសម្បត្តិក្នុងឆ្នាំ១៩០៦ បានរក្សាទំនាក់ទំនងយ៉ាងជិតស្និតជាមួយបារាំង ពេញមួយរាជ្ជកាលរបស់ព្រះអង្គ។ នៅក្នុងរជ្ជកាលនេះហើយដែលមានក្នុងឆ្នាំ១៩២០ក្រមរដ្ឋប្បវេណីកម្ពុជា ត្រូវបានប្រកាសឲ្យប្រើ បទប្បញ្ញត្តិ ទាំងឡាយនៃក្រមរដ្ឋប្បវេណីនេះទាក់ទងទៅនិងសិទ្ធិលើទ្រព្យសម្បត្តិដែលភាគច្រើនយកតាមក្រមរដ្ឋប្បវេណីរបស់បារាំង។[2] បទប្បញ្ញត្តិទាំងនេះបានចែងអំពីភាពខុសគ្នារវាងអចលនវត្ថុ និង

[1] Matthew Rendall, Jose Trembly, និង Patricia Baars, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវកែសម្រួល(ភ្នំពេញ East–West Management Institute, Inc,2005,២២*(តទៅហៅថា ច្បាប់ភូមិបាល សៀវភៅសិក្សា និងស្រាជ្រាវ) ។

[2] ក្រមរដ្ឋប្បវេណី, ឆ្នាំ១៩២០។

ចលនវត្ថុ និយមន័យនៃកម្មសិទ្ធិនិងសិទ្ធិភោគៈ។ ជាលទ្ធផលនៃការអនុម័តក្រមរដ្ឋប្បវេណីនេះ បានធ្វើឲ្យច្បាប់ខ្មែរមុនៗ ស្តីពីទ្រព្យត្រូវបានកែប្រែយ៉ាងច្រើន។ ឆ្លងតាមការអនុវត្តទស្សនៈច្បាប់ បច្ចឹមប្រទេសនេះព្រះមហាក្សត្រលែងមានសិទ្ធិធ្វើជាម្ចាស់លើដីធ្លីនៅក្នុងរាជាណាចក្រកម្ពុជាទៀតហើយ កម្មសិទ្ធិឯកជនត្រូវបានកំណត់ថាជាសិទ្ធិអាស្រ័យផលនិងសិទ្ធិលក់ទ្រព្យសម្បត្តិ សិទ្ធិនេះជាសិទ្ធិដាច់ខាតនិងសិទ្ធិផ្តាច់មុខ។ ប៉ុន្តែសិទ្ធិទាំងនេះត្រូវអនុវត្តក្នុងព្រំដែនកំណត់និងលក្ខខណ្ឌច្បាប់។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧បានទទួលស្គាល់សិទ្ធិដាច់ខាតនិងសិទ្ធិផ្តាច់មុខលើកម្មសិទ្ធិនេះ។ ទោះបីជាយ៉ាងណាក៏ដោយមានទស្សនៈមួយនៃច្បាប់ខ្មែរពីសម័យមុនត្រូវបានរក្សាទុកការបង្ហាញអំពីគោលការណ៍ច្បាប់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ទស្សនៈនេះ មានការពាក់ព័ន្ធទៅនឹងតួនាទីនៃភោគៈក្នុងការទទួលស្គាល់របស់ភោគីលើដីធ្លី។ ដូចបានលើកឡើងខាងលើពាក់ព័ន្ធទៅនិង«ភោគៈ»មាននិយមន័យពិសេសមួយរួចទៅហើយអនុលោមតាមច្បាប់ខ្មែរសម័យមុនដែលបានទទួលស្គាល់ភោគៈនៃដីពេលដែលដីនោះត្រូវបានបង្កបង្កើនផល រុករាន ធ្វើរបង។ ល។ ដោយសារកាលៈទេសៈទាំងនេះហើយ យើងអាចសន្និដ្ឋានបានថាអត្ថន័យដែលបានកំណត់សម្រាប់ពាក្យ ភោគៈ ក្នុងច្បាប់ខ្មែរសម័យមុនត្រូវបានប្រើប្រាស់ដើម្បីបកស្រាយបទប្បញ្ញត្តិនានានៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ការអនុម័តក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ គឺមានគោលបំណងបង្កើតប្រព័ន្ធអភិរក្សសុរិយោដីមជ្ឈការមួយ។ គោលបំណងនេះ គឺដើម្បីបង្កើតប្រព័ន្ធចុះបញ្ជីសុរិយោដីមួយទូទាំងប្រទេសចំពោះការចុះបញ្ជីជាលាយលក្ខណ៍អក្សរ និងក្លាយជាភស្តុតាងនៃសិទ្ធិផ្សេងៗដូចជាកម្មសិទ្ធិករ ភោគៈនិងហ៊ីប៉ូតែក។ ប៉ុន្តែគោលបំណងនេះ មិនដែលបានសម្រេចឬទទួលបានជោគជ័យទាល់តែសោះដោយសារតែប្រព័ន្ធនេះមិនត្រូវបានអនុវត្តទូទាំងប្រទេស។ នៅទីកន្លែងដែលមិនមានការិយាល័យអភិរក្ស សុរិយោដីម្ចាស់ដីត្រូវចុះបញ្ជីនៅទីស្នាក់ការឃុំ -សង្កាត់។[3]

[3] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, ទំព័រ២២។

**១.១.១.៣. កម្ពុជាសម័យឯករាជ្យ**

ក្រោមព្រះរាជបូជនីយកិច្ចរបស់ព្រះបាទនរោត្តមសីហនុ ប្រទេសកម្ពុជាបានទទួលឯករាជ្យក្នុងឆ្នាំ១៩៥៣។[4] ក៏ប៉ុន្តែប្រទេសកម្ពុជា ជាប្រទេសដែលប្រើប្រព័ន្ធច្បាប់ Romano- Germanic អស់ រយៈពេលជាង៣០ឆ្នាំ និងបន្តអភិវឌ្ឍន៍ជាលំដាប់។ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលពាក់ព័ន្ធ និង ព្រទ្យសម្បត្តិតែអនុវត្តក្នុងរយៈពេលនេះ។

**១.១.១.៤.កម្ពុជាប្រជាធិបតេយ្យ**

របបដីបានផ្លាស់ប្តូរយ៉ាងគំហុកពីឆ្នាំ១៩៧៤-១៩៧៩ ដែលជាសម័យកាលមួយស្ថិតក្នុងរបប កម្ពុជាប្រជាធិបតេយ្យ។ ជាប្រវត្តិសាស្ត្រកម្ពុជាសម័យនោះមិនមានច្បាប់ស្តីពីទ្រព្យសម្បត្តិទេហើយ ឯកសារនានាក៏ត្រូវបានបំផ្លាញចោលអស់ដែរ។ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់អចលន វត្ថុ រួមទាំងមធ្យោបាយផលិតកម្មសំខាន់ៗទូទៅផ្សេងទៀត គឺជាទ្រព្យសម្បត្តិ របស់សមូហភាព។[5]

**១.១.១.៥.របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា**

សិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនមិនត្រូវបានទទួលស្គាល់ដោយច្បាប់ ស្ទើរតែពេញមួយរបប នេះ។ ប៉ុន្តែប្រភេទនៃកម្មសិទ្ធិសមូហភាពលើដីលំនៅដ្ឋានត្រូវបានអនុញ្ញាត។[6] បានចែកប័ណ្ណកម្ម សិទ្ធិលើផ្ទះសម្បែងអាចចេញជូនបុគ្គលម្នាក់ៗ ហើយប័ណ្ណលើផ្ទះសម្បែងនេះអាចធ្វើការផ្ទេរតាម រយៈមតកសាសន៍ឬការលក់។[7]

ក្រោយមកទៀតមានការអនុវត្តគោលនយោបាយប្រើប្រាស់ និងគ្រប់គ្រងដីធ្លីបានទទួល ស្គាល់កម្មសិទ្ធិលើដីលំនៅដ្ឋាន។[8] លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់សិទ្ធិកម្មមិនមានចែងនៅក្នុង សេចក្តីណែនាំនេះទេ។ ចំពោះដីស្រែ និងដីកសិកម្មក៏ត្រូវបានអនុញ្ញាតឲ្យមានសិទ្ធិភោគៈលើដីនោះ ដែរតាមមាត្រា១០ នៃសេចក្តីណែនាំបានទទួលស្គាល់សិទ្ធិភោគៈនៃជនដែលកាន់កាប់ និងប្រើ

---

[4] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០,ទំព័រ២៥។

[5] រដ្ឋធម្មនុញ្ញាកម្ពុជាប្រជាធិបតេយ្យ, មាត្រា ២។

[6] អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនដល់ប្រជាពលរដ្ឋ, លេខ២៥អនក្រ, ២២ មេសា ១៩៨៩,មាត្រា១(តទៅហៅថា អនុក្រឹត្យឆ្នាំ១៩៨៩។

[7] អនុក្រឹត្យឆ្នាំ១៩៨៩, មាត្រា២។

[8] សេចក្តីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី, លេខ ០៣ សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ១៩៨៩។

ប្រាស់ដីនោះ។ សេចក្ដីណែនាំលេខ ០៣ បានបញ្ជាក់អះអាងជាគោលការណ៍ថា ភោគៈត្រូវតែពាក់ព័ន្ធជាពិសេសទៅនឹងការប្រើប្រាស់ដី។ សិទ្ធិភោគៈត្រូវបានទទួលស្គាល់ចំពោះស្រែ និងដីកសិកម្មដែលតិចជាង ៥ហិកតា។ ចំពោះដីដាំដំណាំគឺធំជាង ៥ហិកតា សេចក្ដីណែនាំចែងអំពី ភោគៈដែលបានផ្ដល់ក្នុងទម្រង់ជាសម្បទាន។ នៅទីបំផុតយើងគួរបញ្ជាក់ផងដែរថាសេចក្ដីណែនាំ មានគោលបំណងបង្កើតនូវប្រព័ន្ធសម្រាប់ការប្រកាស និងការចុះបញ្ជីភោគៈ។

**១.១.១.៦. សម័យរដ្ឋកម្ពុជា**

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ភូមិបាលថ្មី (ច្បាប់ភូមិបាលឆ្នាំ១៩៩២)។ និយមន័យនៃពាក្យកម្មសិទ្ធិ អនុលោមតាមមាត្រា១៩ បានចែងឡើងវិញនូវគោលការណ៍ច្បាប់នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។[9]និយមន័យនោះ គឺកម្មសិទ្ធិមានន័យថាជាសិទ្ធិអាស្រ័យផល និងសិទ្ធិលើទ្រព្យសម្បត្តិ។ សិទ្ធិនេះជាសិទ្ធិដាច់ខាតនិងផ្ដាច់មុខ ប៉ុន្តែត្រូវអនុវត្តក្នុងព្រំដែននិងលក្ខខណ្ឌដែលច្បាប់បានកំណត់។ ច្បាប់ភូមិបាលឆ្នាំ១៩៩២ នេះបានស្ដែងឲ្យឃើញពីការកើតមានឡើងវិញនូវកម្មសិទ្ធិឯកជនអនុលោមតាមច្បាប់កម្ពុជា។ ប៉ុន្តែច្បាប់ភូមិបាលឆ្នាំ១៩៩២បានបញ្ជាក់ថាមានតែដីលំនៅដ្ឋានមួយគត់អាចជាកម្មសិទ្ធិឯកជន និងដីដែលស្ថិតនៅតំបន់ទីក្រុង ត្រូវបញ្ញាតិតាមច្បាប់ដោយឡែក។[10] ច្បាប់ស្ដីពីការកំណត់តំបន់ទីក្រុងនៅមិនទាន់បានអនុម័តនៅឡើយ។ ជាទូទៅ ច្បាប់ភូមិបាលឆ្នាំ១៩៩២ បានចែងឡើងវិញអំពីគោលការណ៍ច្បាប់នានា ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីមុនៗរបស់កម្ពុជា។ ច្បាប់នេះ ទទួលស្គាល់ការទទួលបាន កម្មសិទ្ធិតាម រយៈសន្តតិកម្ម មរតកសាសន៍ កិច្ចសន្យាលក់ ប្រទានកម្ម និងតាមរយៈភោគៈ។

អនុលោមតាមច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ មធ្យោបាយដើម្បីទទួលបានដីជាគោលការណ៍ គឺមានតែតាមរយៈភោគៈ ដែលបានចាប់ផ្ដើមកាន់កាប់មុនពេលការកាន់កាប់ចូលជាធរមាននៃច្បាប់ភូមិបាលឆ្នាំ២០០១។ ដោយសារហេតុនេះ កម្មវត្ថុនៃភោគៈក្រោមច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវតែមានការបញ្ជាក់ឲ្យបានល្អិតល្អន់ថែមទៀត។ ភោគៈត្រូវបានទទួលស្គាល់[11] ច្បាប់ភូមិបាលឆ្នាំ១៩៩២

[9] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០,ទំព័រ២៥។

[10] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា៦៥ (តទៅហៅថា ច្បាប់ភូមិបាលឆ្នាំ១៩៩២)។

[11] ច្បាប់ភូមិបាល,ឆ្នាំ១៩៩២,មាត្រា៦១ ដល់មាត្រា៧៦។

បានអនុញ្ញាតឲ្យមានកម្មសិទ្ធិ សិទ្ធិតាមរយៈភោគៈ។ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏បានចែងផងដែរថា ដើម្បីក្លាយជាកម្មសិទ្ធិករនៃដីភោគីត្រូវតែបង្ហាញថាភោគៈរបស់ខ្លួន គឺបានមកដោយសន្តិវិធី ដោយសុចរិត ដោយមានការដឹងឮជាសាធារណៈ ដោយមិនមានការអាក់ខាន និងដោយគ្មានការបន្លំ។

លក្ខខណ្ឌទាំងនេះ ស្របទៅតាមទស្សនៈទានស្តង់ដាស្តីពីភោគៈក្នុងបណ្តាប្រទេសដែលអនុវត្តប្រព័ន្ធស៊ីវិល។ លើសពីនេះទៅទៀត ភោគៈត្រូវតែមានរយៈពេលយ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំក្នុងការកាន់កាប់ដីនោះ។ ទាក់ទងនឹងការទទួលបានកម្មសិទ្ធិតាមរយៈភោគៈច្បាប់ភូមិបាលឆ្នាំ ១៩៩២ បានចែងនូវលក្ខខណ្ឌតម្រូវពីរផ្សេងទៀតគឺភោគីត្រូវជូនដំណឹងទៅសាលាឃុំ សង្កាត់ឲ្យបានដឹងឮភោគីត្រូវបង់ពន្ធឲ្យទៀងទាត់។[12]

លក្ខខណ្ឌតម្រូវទាំងនេះក៏មានចែងផងដែរក្នុងមាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ និង ក្នុងមាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីប្រែឆ្នាំ១៩៥១។ ទោះបីយ៉ាងណាមានកត្តាជាច្រើនបាន ប៉ះពាល់ដល់ការអនុវត្តដោយសារតែការកែប្រែច្បាប់ភូមិបាលឆ្នាំ១៩៩២។ បញ្ហាទី១កម្រមានការចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋណាស់ ដូច្នេះប្រជាជនគ្រាន់តែបានចូលកាន់កាប់ដីតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ការផ្លាស់ប្តូរទីកន្លែងច្រើនដងរបស់ប្រជាជន និងផលវិបាកក្នុងការចូលទៅដល់តំបន់មួយចំនួនដែលបង្ករឲ្យមាន ការប៉ះពាល់ដល់លទ្ធភាពការអនុវត្តច្បាប់ភូមិបាល១៩៩២នេះ។ បញ្ហាទី២មានការពិបាកក្នុងការផ្តល់ព័ត៌មានជូនប្រជាជនគ្រប់រូបអំពីកាតព្វកិច្ចតាមច្បាប់ថ្មីស្តីពី ការប្រកាសជូនដំណឹងពីភោគៈរបស់ខ្លួន និងការបង់ពន្ធទៀងទាត់។ ហើយប្រសិនបើប្រជាជនមិនបានទទួលព័ត៌មាន ពួកគាត់មិនអាចអនុវត្តកាតព្វកិច្ចថ្មីទាំងនេះបានឡើយ ដូច្នេះតាមច្បាប់ពួកគាត់មិនអាចទាមទារកម្មសិទ្ធិលើដីដោយផ្អែកលើភោគៈរបស់គាត់បានទេ។ បញ្ហាទាក់ទងដល់ការកែប្រែច្រើនដងជាបន្តបន្ទាប់ រហូតដល់មានការអនុម័តច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ។

[12] ច្បាប់ភូមិបាលឆ្នាំ១៩៩២,មាត្រា១៨។

### ១.១.១.៧.ព្រះរាជាណាចក្រកម្ពុជា

នៅក្នុងឆ្នាំ១៩៩៣ ដោយមានការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញថ្មី កម្ពុជាបានក្លាយជាព្រះរាជាណាចក្រកម្ពុជាមួយបានបង្កើតឲ្យមានរដ្ឋាភិបាលថ្មី។[13] មាត្រា៤៤ នៃរដ្ឋធម្មនុញ្ញាបានបញ្ជាក់សារជាថ្មីស្តីពីសិទ្ធិក្នុងធ្វើជាម្ចាស់លើដីធ្លីប៉ុន្តែការកំណត់សិទ្ធិនេះចំពោះតែប្រជាជនកម្ពុជាតែប៉ុណ្ណោះ។[14] ក្រោយពីការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញា ច្បាប់ថ្មីដើម្បីជំនួសច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏បានប្រកាសឲ្យប្រើនៅឆ្នាំ២០០១ គឺច្បាប់ភូមិបាលឆ្នាំ២០០១។ ចំពោះច្បាប់ភូមិបាលឆ្នាំ២០០១ទទួលស្គាល់តែភោគៈដែលបានចូលកាន់កាប់មុនច្បាប់ភូមិបាលនេះ ចូលជាធរមានតែប៉ុណ្ណោះចំពោះការចូលកាន់កាប់លើអចលនវត្ថុ ក្រោយពីការចូលជាធរមានត្រូវបានចាត់ទុកថាជាការចូលកាន់កាប់ដោយខុសច្បាប់។ ជាចុងក្រោយ នៃបទប្បញ្ញាត្តិច្បាប់ដែលទាក់ទងទៅនិងសិទ្ធិកាន់កាប់ គឺក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលបានអនុម័តឡើងនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ នឹងអាចអនុវត្តបានពេញលេញនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០០១។[15]

### ១.១.២.និយមន័យ នៃសិទ្ធិកាន់កាប់

និយមន័យសិទ្ធិកាន់កាប់ ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លើមាត្រា២២៧ បានចែងថា « ការកាន់កាប់ សំដៅលើការក្តាប់ទុកវត្ថុ។[16] ការក្តាប់ទុកសំដៅលើការគ្រប់គ្រងលើរូប វត្ថុតាមការជាក់ស្តែង ទោះដោយប្រយោងក្តី»។ អត្ថន័យនៃនិយមនេះគេសន្និដ្ឋានបានថាឲ្យតែមានការគ្រប់គ្រងលើរូបវត្ថុនោះ ទោះបីជាដោយចំពោះក្តីឬប្រយោលក្តី គឺច្បាប់កំណត់ថាជនដែលបានគ្រប់គ្រងលើរូបវត្ថុនោះ មានសិទ្ធិកាន់កាប់តាមអ្វីដែលច្បាប់បានកំណត់។ បន្ថែមលើសពីទៅទៀតក្នុងមាត្រានេះផងដែរមិនកំណត់ថា ចំពោះការដែលអាចកាន់កាប់លើវត្ថុណាមួយបាន លុះត្រាតែមានមូលហេតុគតិយុត្តត្រឹមត្រូវស្របតាមនោះទេ។ អាស្រ័យហេតុគេអាចកំណត់ថាចំពោះការដែលទទួលបានសិទ្ធិកាន់កាប់លើវត្ថុណាមួយ មិនទាមទារតែមានមូលហេតុគតិយុត្តលើវត្ថុនោះទេ ពោល

[13] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, វិសោធនកម្ម ១៣ កក្កដា ២០០១៨, មាត្រា១១៩។

[14] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៤៤។

[15] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, ទំព័រ២៧។

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, មាត្រា២២៨ (តទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

គឺទោះបីជាមានមូលហាតុគតិយុត្ត ឬគ្មានមូលហេតុគតិយុត្តក្នុង ការកាន់កាប់វត្ថុនោះក៏ដោយ ក៏អាចទទួលបានសិទ្ធិកាន់កាប់ដែរ ឲ្យតែបានគោរពតាមលក្ខខណ្ឌ ដែលច្បាប់បានកំណត់ គឺការគ្រប់គ្រងលើរូបវត្ថុនោះ។

ចំពោះនិយមន័យ នៃសិទ្ធិកាន់កាប់បានបញ្ជាក់ច្បាស់លាស់ហើយថា កម្មវត្ថុនៃសិទ្ធិកាន់កាប់គឺមានតែវត្ថុប៉ុណ្ណោះ។ ដោយពាក្យថា **វត្ថុ** នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់និយមន័យថាវត្ថុសំដៅទៅលើរបស់ដែលមានរូបរាងជាសារធាតុឧស្ម័ន ជាសារធាតុរឹង។[17] ទាញចេញពីនិយមន័យនេះដើម្បីអាចក្លាយជាវត្ថុបាន គឺទាល់តែមានធាតុផ្សំចំនួន២គឺទី១ ត្រូវតែមានរូបរាងនិងទី២ ជាសាធាតុរឹង។ បន្ថែមពីនេះទៅទៀត ក្នុងក្រមរដ្ឋប្បវេណីក៏បានបែងចែងជា២ ប្រភេទដែរគឺ[18] អចលនវត្ថុសំដៅទៅលើដីធ្លីនិងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែង បានដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ។ មានន័យថាជាវត្ថុដែលអាចរំកិល ឬអាចប្តូរផ្លាស់ទីតាំងបានដូចជា របស់របរផ្ទាល់ខ្លួន ឬចលនទ្រព្យដែលជាកម្មសិទ្ធិ ហើយមិនត្រូវបានគេចាត់ទុកប្រភេទជាអចលនវត្ថុ។ ឧទាហរណ៍ ម៉ូតូ ឡាន ...។ លើសពីនេះទៅទៀតចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រង់បានបញ្ញត្តិ ស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នា លើកលែងមានបញ្ញត្តិក្នុងច្បាប់ពិសេស។

### ១.១.៣.ប្រពភ នៃសិទ្ធិកាន់កាប់

សិទ្ធិកាន់កាប់ គឺជាសិទ្ធិដែលច្បាប់ផ្តល់ឲ្យបុគ្គលគ្រប់រូបទាំងអស់ដែលបានក្តាប់ទុកវត្ថុ នោះតាមភាពជាក់ស្តែង។ ម្យ៉ាងវិញទៀតក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សិទ្ធិកាន់កាប់ដែលច្បាប់ផ្តល់ឲ្យចំពោះអចលនវត្ថុជាដើម គឺមានតែប្រភេទដីដែលមានកម្មសិទ្ធិប៉ុណ្ណោះ ចំណែកដីដែលជាកម្មសិទ្ធិរបស់រដ្ឋវិញ ទោះបីជាបានក្តាប់ទុកដីនោះតាមភាពជាក់ស្តែងក៏ដោយ ក៏ច្បាប់មិនទទួលស្គាល់សិទ្ធិ

ការកាន់កាប់ដោយមូលហេតុគតិយុត្ត គឺសំដៅទៅលើស្ថានភាពដែលការក្តាប់ទុកវត្ថុនោះមានភាពត្រឹមត្រូវតាមច្បាប់កំណត់ដូចជា ការកាន់កាប់ដោយផ្អែកលើកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍

[17] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១៩៩។
[18] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១២០។

ផលុបភោគ សិទ្ធិលើការបញ្ចាំ ជាអាទិ៍។

ការកាន់កាប់ដោយគ្មានមូលហេតុគតិយុត្ត គឺសំដៅទៅលើស្ថានភាពដែលការក្តាប់ទុកវត្ថុនោះមិនមានភាពត្រឹមត្រូវស្របតាមច្បាប់កំណត់ ឬ អាចនិយាយថាបានជាក្តាប់ទុកវត្ថុ ដោយមិនមានសិទ្ធិគតិយុត្តណាមួយនោះទេ។ បើនិយាយក្នុងន័យសាមញ្ញ គឺជាការចូលទៅកាន់កាន់វត្ថុរបស់អ្នកដ៍ទៀតដោយរំលោភបំពាន។

**១.១.៤. រចនាសម្ព័ន្ធនៃសិទ្ធិកាន់កាប់**

សិទ្ធិកាន់កាប់ បានបញ្ញត្តិក្នុងគន្ថីទី៣ នៃសិទ្ធិប្រត្យក្ស នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចាប់ពីមាត្រា២២៧ដល់មាត្រា២៤៣។




រូប១៖ រចនាសម្ព័ន្ធនៃសិទ្ធិប្រត្យក្ស ផ្អែកតាមទីតាំងក្នុងក្រមរដ្ឋប្បវេណី

រូប២៖ រចនាសម្ព័ន្ធនៃសិទ្ធិកាន់កាប់ ផ្អែកតាមតាំងក្នុងសិទ្ធិប្រត្យក្ស



# ជំពូកទី២

# កំណើនប្រជាពលរដ្ឋបាត់បង់សិទ្ធិកាន់កាប់ដីធ្លី

## ២.១. ការកាន់កាប់ដីធ្លីគ្មានប័ណ្ណកម្មសិទ្ធិ

បញ្ហាដីធ្លីនៅតែជារឿងចម្រូងចម្រាស់មួយនៅប្រទេសកម្ពុជា។ របបកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ ត្រូវបានលុបចោល។ អ្នកដែលកាន់កាប់ដីធ្លី ក្រោយឆ្នាំ១៩៧៩ នៅតែមានច្រើនដែលកាន់កាប់ដោយគ្មានប័ណ្ណសម្គាល់កម្មសិទ្ធិ។[19] ជាហេតុមួយដែលនាំឲ្យប្រជាពលរដ្ឋភាគច្រើនកាន់កាប់ដីធ្លី ដោយមិនមានប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់ដីធ្លី។ ប៉ុន្តែបុគ្គលណាដែលកាន់កាប់ដីធ្លី មុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន និងការកាន់កាប់ដោយគ្មានប័ណ្ណសម្គាល់កម្មសិទ្ធិ ប៉ុន្តែការកាន់កាប់នោះក្នុងនាមជាភោគៈ។

### ២.១.១. ការកាន់កាប់ដីធ្លីមុនច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន

ដោយឡែកបុគ្គលទាំងឡាយណាដែលកាន់កាប់ដីធ្លី មុនច្បាប់ភូមិបាលឆ្នាំ២០០១ ប្រកាសឲ្យប្រើប្រាស់ គឺជាក្នុងជាភោគៈតែប៉ុណ្ណោះ។ សិទ្ធិភោគៈ គឺជាប្រភេទដែលមានលក្ខណៈ សឹងតែដូចគ្នាបំផុតទៅនឹងនិងកម្មសិទ្ធិករ។ ជាការពិតណាស់ ក្នុងការអនុវត្តជាក់ស្តែងមានសិទ្ធិពីរប្រភេទមានលក្ខណៈសឹងតែដូចគ្នាបំផុតដែលឲ្យយើងមានការពិបាកក្នុងការរកមើលឲ្យឃើញនូវភាព ខុសគ្នារវាង កម្មសិទ្ធិករនិងភោគៈ។ ករណីដែលអាចក្លាយជាភោគៈបានលុះត្រាតែបានបំពេញ លក្ខខណ្ឌមួយចំនួន ១.ចូលកាន់កាប់ដោយសន្តិវិធី ២.កាន់កាប់អចលនវត្ថុដោយពិតប្រាកដ ៣.កាន់កាប់ដោយគ្មានហិង្សា ៤.កាន់កាន់ដោយដឹងឮជាសាធារណៈ ៥.កាន់កាប់ដោយគ្មាន ការអាក់ខាន។[20] ថ្វីត្បិតតែមានសិទ្ធិប្រហាក់ប្រហែលទៅនឹងកម្មសិទ្ធិករក៏ពិតមែន ប៉ុន្តែដែលអាចធ្វើឲ្យភោគៈបាត់បង់សិទ្ធិក្នុងការកាន់កាប់ដីធ្លីនោះគឺ ការពារក្នុងផ្លូវច្បាប់។ មានន័យថា ភោគីគឺជាសិទ្ធិ ដែលមានលក្ខណៈបណ្តោះអាសន្ន ដែលអាចមានការជំទាស់តវ៉ាបានទៅថ្ងៃក្រោយ។

---

[19] ច្បាបភូមិបាលឆ្នាំ២០០១, មាត្រា៧។

[20] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា ៣៨។

ដើម្បីសបញ្ជាក់ឲ្យឃើញថាការកាន់កាប់ដីមុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន មិនប្រាកដថាក្លាយជាភោគីស្របច្បាប់ទេ វៀរលែងតែបានបំពេញលក្ខខណ្ឌទាំង៥ និងបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិពីអាជ្ញាធរមានសមត្ថកិច្ច តាមផ្លូវច្បាប់បានចែង។

ជាមូលហេតុមួយដែលធ្វើឲ្យបុគ្គលដែលកាន់កាប់ដីធ្លីមុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន នឹងត្រូវបាត់បង់សិទ្ធិក្នុងការកាន់កាប់ដីធ្លី ដោយមិនបានបំពេញជាលក្ខខណ្ឌជាភោគីស្របច្បាប់។

### ២.១.២. ការកាន់កាប់ដីធ្លីក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ រាល់ការកាន់កាប់ដីធ្លី ជាលក្ខណៈបែបភោគៈគ្មានទៀតទេ មានន័យថា បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ២០០១[21]ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការរាល់ការកាន់កាប់បែបភោគៈមិនត្រូវបានអនុញ្ញាតឲ្យមានទៀតឡើយទៅក្នុងរូបភាពបែបណាក៏ដោយ។ រាល់ការចូលកាន់កាប់អចលនវត្ថុ នៅក្រោយច្បាប់ភូមិបាលចូលជាធរមាន គឺជាការកាន់កាប់ខុសច្បាប់ ដែលអាចទទួលទោសព្រហ្មទណ្ឌ ប៉ុន្តែប្រជាពលរដ្ឋ ដែលមានបំណងចង់បានដីនោះ ត្រូវតែដាក់ពាក្យស្នើសុំទៅអាជ្ញាធរ តាមរយៈយន្តការសម្បទានដីសង្គមកិច្ច។ បុគ្គលណាដែលចូលកាន់កាប់ដីរដ្ឋក្តី ដីឯកជនក្តី ដីសមូហភាពក្តី ដោយមិនស្របច្បាប់នោះ មិនមានសិទ្ធិក្នុងការគ្រប់គ្រងអចលនវត្ថុនោះឡើយ។ ប៉ុន្តែអាចមានសិទ្ធិក្នុងការគ្រប់គ្រងដីនោះបានតាមរយៈ សម្បទានដីសង្គមកិច្ច សម្បទានដីសេដ្ឋកិច្ច តាមការជួល លក់ ជាដើម។

ករណីដែលបុគ្គលណាចូលកាន់កាប់ដីធ្លីបន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន ច្បាប់មិនអនុញ្ញាតឲ្យសិទ្ធិក្នុងការគ្រប់គ្រងនោះឡើយ។ មានន័យថាសិទ្ធិកាន់កាប់របស់បុគ្គលនោះត្រូវបានច្បាប់ហាមឃាត់ សិទ្ធិកាន់កាប់ (ការសិទ្ធិកាន់កាប់មិនស្របច្បាប់)។

[21] ច្បាប់ភូមិបាលឆ្នាំ២០០១។

## ២.២. បញ្ហាវិវាទដីធ្លី

ការកើនឡើងនៃតម្លៃអចលនទ្រព្យជាពិសេសនោះ គឺដីធ្លីត្រូវបានគេសង្កេតឃើញថានៅចន្លោះឆ្នាំ២០០៧និងឆ្នាំ២០០៨ មុនការបោះឆ្នោតនៅកម្ពុជានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨[22] និងនៅចន្លោះឆ្នាំ២០១៧និងឆ្នាំ២០១៨ តម្លៃដីធ្លីមានការកើនឡើងដល់កម្រិតដ៏ខ្ពស់[23] ដោយសារមានចលនានៃការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងអាគារសំណង់ផ្សេងៗព្រមទាំងការពង្រីកទីក្រុងមួយចំនួនផងដែរ។ ប្រកាសនេះបានធ្វើឲ្យបុគ្គលដែលមានដីធ្លី ដូចជាដីស្រែ ដីកសិកម្ម ដីទំនេរ លក់ក្នុងតម្លៃទីផ្សាពេលនោះ ហើយក្លាយជាអ្នកមានចំនួនធំ។ ផ្ទុយទៅវិញក៏មាននូវទំនាស់យ៉ាងខ្លាំងផងដែរដែលទាក់ទងនឹងសិទ្ធិលើកម្មសិទ្ធិដីធ្លី ហើយករណីវិវាទដីធ្លីនោះ ត្រូវបានដឹងឮទូទៅថាជាបញ្ហាក្តៅ គគុកនៅក្នុងសង្គមកម្ពុជា។ ដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំង ពីសំណាក់ប្រជាជនកម្ពុជារួមទាំងរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋបាលភិបាល ដៃគូរអភិវឌ្ឍន៍ជាមួយរដ្ឋបាភិបាល ម្ចាស់ជំនួយ និងសង្គមស៊ីវិលផ្សេងៗទៀត ហើយក៏ក្លាយជាប្រធានបទសម្រាប់រាជរដ្ឋាភិបាលដោះស្រាយ រហូតមកដល់នាពេលបច្ចុប្បន្ន។

បន្ទាប់ពីច្បាប់ភូមិបាលត្រូវបានអនុម័តនៅឆ្នាំ២០០១ យើងឃើញថាបញ្ហាវិវាទដីធ្លីនៅតែកើតមានដូចដែលធនាគារពិភពលោកបានធ្វើការកត់សម្គាល់នៅឆ្នាំ២០០៣ ថាការបរាជ័យក្នុងការអនុវត្តច្បាប់នានា ទាក់ទងដីធ្លីនិងធនធានធម្មជាតិ ដោយសារតែការអនុវត្តជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំពោះជីវិភាពរបស់ពួកគាត់ ដែលជាមូលហេតុឲ្យកើតមានឡើង។[24] មានន័យថា ការកាន់កាប់ដីធ្លីភាគីច្រើននៅតែមិនមានសុវត្ថភាព។ ដូចជាករណីវិវាទដីធ្លីនៅ ភូមិអូរល្លិព្រងខេត្តបាត់ដំបង ដែលបានកើតឡើងអស់រយៈពេលជិត ១៥ ឆ្នាំរវាង លោក អៀង អឿន ជាអាជីវករដែលបានអះអាងថាជាកម្មសិទ្ធិរបស់គាត់ បានដាក់ពាក្យបណ្តឹងមួយប្រឆាំងនិងអ្នកភូមិពីបទកាន់

[22] https://opendevelopmentcambodia.net/km/topics/elections/ (ទស្សនាចុងក្រោយ ខែមេសា ២០១៩)។

[23] https://www.construction-property.com/read-news-1020/ (ទស្សនាចុងក្រោយ ខែមេសា ២០១៩)។

[24] វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល,ការវិភាគទិន្នន័យស្តីពីករណីវិវាទដីធ្លីនៅកម្ពុជាក្នុងឆ្នាំ២០០៩ ,ទំព័រទី២ កថាខណ្ឌទី២(ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

កាប់ដី១៩ហិកតា ដោយខុសច្បាប់នៅឆ្នាំ១៩៩៨ ហើយនៅឆ្នាំ១៩៩៨ តុលាការខេត្តបានសម្រេចឲ្យគាត់ឈ្នះនិងប្រគល់ដី។ ក្នុងឆ្នាំ២០០២គាត់បានដាក់ពាក្យបណ្តឹងមួយទៀត ប្រឆាំងទៅនឹង៧គ្រួសារថែមទៀត ពីបទទន្ទ្រានកាន់កាប់ដីរបស់គាត់ ហើយតុលាការក៏ប្រើប្រាស់ សាលក្រមដំបូង។ ក្នុងឆ្នាំ២០០៥លោកអៀង អឿន បានដាក់ពាក្យបណ្តឹងមួយទៀតប្រឆាំងនិងមនុស្ស ៩នាក់។ អ្នកទាំង៩ នាក់នេះត្រូវបានឃុំខ្លួនមុនការជម្រះ។ ក្នុងឆ្នាំ២០០៧ អ្នកភូមិ មានសិទ្ធិកាន់កាប់លើដីធ្លីនោះដែល លោកអៀង អឿន ពុំមានសិទ្ធិតាមផ្លូវច្បាប់បានក្នុងឆ្នាំ១៩៩៨ (ព្រោះតំបន់នេះគ្រប់គ្រងដោយពួកខ្មែរក្រហម)ហើយថា គ្មានមូលដ្ឋានក្នុងការឃុំខ្លួនអ្នកភូមិទេ។ ខែវិច្ឆិការ ឆ្នាំ២០១២តុលារការសម្រេចចាប់ខ្លួនប្រជាជន៩នាក់ពាក់ព័ន្ធឹងករណីនេះ។ អ្នកភូមិម្នាក់ក្នុងចំណោមជនជាប់ចោទ៩នាក់ ត្រូវបានបញ្ជូនមកតុលាការខេត្ត នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១៣។[25]

ស្រដៀងគ្នានេះដែរ ក៏មាន«ករណីវិវាទដីធ្លីកើតឡើងនៅភូមិអូធឿង សង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដែលផលដំណាំនិងទ្រព្យសម្បត្តិប្រជាពលរដ្ឋចំនួន ៩០គ្រួសារ ត្រូវបានរឹបអូសនឹងឈូសបំផ្លាញចោល កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ ដោយកម្លាំងសមត្ថកិច្ចចម្រុះ ក្រុងព្រះសីហនុ ដែលអះអាងថាជាដីកម្មសិទ្ធិរបស់ អៀ ម៉េងស៊ីន ដែលបានទិញពី លោក តឹក ងួន និងលោក សំ ផា ចៅសង្កាត់វេទី២។ ក្នុងឆ្នាំ២០០៥អ្នកទាំងពីនាក់ បានមកសុំចែកដីពីប្រជាពលរដ្ឋដោយសន្យាថានិងធ្វើការអភិវឌ្ឍក្នុងតំបន់នោះ។ ប្រជាពលរដ្ឋបានឲ្យដឹងថា ពួកគាត់បានរស់នៅទីនោះតាំងឆ្នាំ១៩៩៣ ដោយបានកាប់រានព្រៃដើម្បីធ្វើស្រែចំការ និងសង់លំនៅដ្ឋាន ហើយអះអាងថាជាការរស់នៅដោយស្របច្បាប់ ដោយមានសៀវភៅគ្រួសារ លិខិតស្នាក់នៅ និងមានបង្កាន់ដៃសុំកាន់កាប់ដីធ្លីទៀតផង។ លោក ឡាក់ គៀន ចៅសង្កាត់បិតត្រាំង បានអះអាងថា ការទិញលក់ដីរបស់លោក អៀ ម៉េងស៊ីន មិនត្រឹមត្រូវទេ លើសពីនេះទៀត មានតែប្រជាពលរដ្ឋមួយចំនួនប៉ុណ្ណោះ

[25] សមាគមអាដហុក, ផ្លូវបត់ សិទ្ធិដីធ្លី និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា,ខែ កុម្ភៈ ឆ្នាំ២០១៣ ទំព័រ២២, (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

ដែលបានលក់ដី តែផ្ទុយទៅវិញ្ញាបែរជាលោក តឹក ងួន មានប្លង់ដីដែលបានទិញពីប្រជាពលរដ្ឋរហូតដល់ទំហំ ៥៨៥ ហិកតា។

អ្នកភូមិជាង១០០គ្រួសារនៅភ្នំពេញដែលមានជម្លោះដីធ្លីជាមួយទាហាន ផ្ទុះការតវ៉ាជាថ្មី។

អ្នកភូមិ១៩៥គ្រួសារដែលកំពុងមានជម្លោះដីធ្លីជាមួយបន្ទាយទាហានក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញបានផ្ទុះការតវ៉ាជាថ្មីក្រោយរង់ចាំដំណោះស្រាយជិត២០ឆ្នាំ។ ពលរដ្ឋប្រមាណ៧០នាក់ តំណាងឲ្យពលរដ្ឋ១៩៥គ្រួសារដែលមានជម្លោះដីធ្លីជាមួយទាហានវរៈសេនាតូចការពារអាកាស លេខ៩១ ស្ថិតក្នុងភូមិព្រៃទា សង្កាត់ចោមចៅបានប្រមូលផ្តុំគ្នាមុខសាលាពោធិ៍សែនជ័យនៅថ្ងៃនេះ ដើម្បីជំរុញទៅអាជ្ញាធរខណ្ឌមួយនេះ ជួយពន្លឿនរកដំណោះស្រាយជូនពួកគេ។ ដោយពួកគាត់មិនទាន់បានទទួលដំណោះស្រាយសមរម្យណាមួយឡើយ។[26]

វិវាទដីនៅមានតំបន់ជាច្រើនទៀតបានកើតឡើង ដែលមិនទាន់បានទទួលនូវដំណោះស្រាយនៅឡើយ។ យើងនិងធ្វើស្រាយបញ្ជាក់ពីមូលហេតុដែលនាំឲ្យកើតមានឡើងនូវវិវាទដីធ្លីនៅកម្ពុជា ដូចខាងក្រោម។

### ២.២.១.ប្រភេទនៃករណីវិវាទដីធ្លី

វិវាទដីធ្លីកើតឡើងនៅគ្រប់តំបន់ផ្សេងៗគ្នា ដែលមាននៅលើដីកសិកម្មរួមមានដីសម្រាប់ បង្កបង្កើនផលដីចម្ការឬដីលំនៅដ្ឋាន ឬអាចជាដីព្រៃ និងដីផ្សេងៗទៀតដូចជាត្រពាំងសហគមន៍ ព្រៃលិចទឹក ដីវត្ត ដីសហគមន៍ ឬដីដែលធ្លាប់ត្រូវបានប្រើជាដីផ្លូវសហគមន៍ជាដើម។ តែទោះជាយ៉ាងណាក៏ដោយ វិវាទដីធ្លីភាគច្រើនមាននៅលើដីប្រភេទកសិកម្ម ដីព្រៃ និងដីលំនៅដ្ឋាន។[27]

ផ្អែកតាមក្រហ្វិកនេះ យើងឃើញថាវិវាទលើដីកសិកម្ម មានច្រើនជាងគេ រហូតដល់ ៥៣% (តំណាងដោយករណីវិវាទ ចំនួន៥១) ដីប្រភេទលំនៅដ្ឋាន មាន២៥% (តំណាងដោយករណីវិវាទចំនួន៦៨)

---

[26] https://vodhotnews.com/2019/06/26/101923/more-100-families-phnom-penh-who-been-displacing-91-soldiers-blasted-protests/ (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

[27] វេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា,ការវិភាគទិន្និន័យស្តីពីករណីវិវាទដីធ្លីនៅកម្ពុជា,(២០១០)៧, ២(ទស្សនាចុងក្រោយ នៅខែ មេសា ២០១៩)។

និងដីព្រៃចំនួន ១០% (តំណាងដោយករណីវិវាទចំនួន ២៨)។ផ្អែកតាមក្រហ្វិកនេះ យើងឃើញថា វិវាទលើដីកសិកម្ម មានច្រើនជាងគេ រហូតដល់ ៥៣% (តំណាង ដោយករណីវិវាទ ចំនួន៥១) ដីប្រភេទលំនៅដ្ឋាន មាន២៥% (តំណាងដោយករណីវិវាទចំនួន៦៨) និងដីព្រៃចំនួន ១០% (តំណាងដោយករណីវិវាទចំនួន ២៨)។[28]




ករណីវិវាទដីធ្លីបានកើតឡើងតាំងពីយូរមកហើយ អាចនិយាយបានថាតាំងពីឆ្នាំ១៩៩០ នៅពេលដែលមានរបត់នយោបាយឈានទៅរកឯកជន ភាវូបនីយកម្ម ទីផ្សារសេរី និងសាកលភាវូបនីយកម្ម រហូតដល់បច្ចុប្បន្ន ដែលមានករណីវិវាទដីធ្លីមួយចំនួនត្រូវបានដោះស្រាយនិងមួយចំនួធំ ដែលមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ ដែលបញ្ហានេះនាំទៅដល់ការបណ្តេញចេញការបង្ខំ ការកាត់ទោស រហូតដល់ការដាក់គុកជាដើម។ តើរដ្ឋាភិបាលមានយន្តការយ៉ាងដូចម្តេច ដើម្បីដោះស្រាយ?តើមានប្រព័ន្ធច្បាប់រួចហើយឬនៅសម្រាប់ការអន្តរាគមន៍ជួយដោះស្រាយ

### ២.២.២. ដីធ្លីមិនទាន់បានចុះបញ្ជី

សិទ្ធិទទួលបានអចលនវត្ថុឯកជនត្រូវបានបង្កើតឡើងជាផ្លូវការក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣[29] ប៉ុន្តែក្របខណ្ឌគ្របដណ្តប់លើសិទ្ធិទាំងនោះមិនត្រូវបានបង្កើតឡើងនោះទេ រហូតដល់ការអនុម័ត

[28] https://opendevelopmentcambodia.net/km/topics/land-tenure-and-titling/ (ទស្សនាចុងក្រោយ នៅខែមេសា ២០១៩)។
[29] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៤៤។

ច្បាប់ភូមិបាល ឆ្នាំ២០០១។ ក្នុងគោលបំណងចុះបញ្ជីដីធ្លីទាំងអស់ជាប្លង់រឹងដែលមានការទទួលស្គាល់ថ្នាក់ជាតិជាលទ្ធផល កម្ពុជាមានប្រព័ន្ធកម្មសិទ្ធិដីធ្លីពីរ ដែលមានទាំងប្លង់ "ទន់" និងប្លង់ "រឹង។ ប្លង់ទន់ គឺសម្រាប់សម្គាល់សិទ្ធិដីធ្លីដែលត្រូវបានចុះបញ្ជីជាមួយឬទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានឬស្រុក។ នៅក្រោមក្របខ័ណ្ឌច្បាប់ភូមិបាលឆ្នាំ ២០០១ ប្លង់ទន់មិនផ្តល់សិទ្ធិកម្មសិទ្ធិស្របច្បាប់ឡើយ។ ប៉ុន្តែវាជាការទទួលស្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។

អ្នកកាន់កាប់ដីដែលមិនមានប្លង់រឹង អាចមានសិទ្ធិលើដីធ្លីនោះក្នុងនាមជាភោគីស្របច្បាប់។ ភោគៈស្របច្បាប់ គឺគ្រាន់តែជាសិទ្ធិបណ្តោះអាសន្ន ដែលភោគីមានសិទ្ធិស្រដៀងគ្នានឹងម្ចាស់កម្មសិទ្ធិករដែរ។ ភោគីអាចផាត់ចេញ ផ្ទេរ សាងសង់ កែលម្អរចនាសម្ព័ន្ធ និងប្រើប្រាស់ដីធ្លីសម្រាប់ដាក់ធានា។ យោងតាមច្បាប់ភូមិបាលឆ្នាំ ២០០១ បុគ្គលទាំងឡាយណាដែលចាប់កាន់កាប់ដី មុនការអនុម័តលើច្បាប់នេះ អាចមានសិទ្ធិកាន់កាប់ស្របច្បាប់ ដរាបណាការកាន់កាប់នោះបំពេញតាមលក្ខខណ្ឌមួយចំនួន។ ម្ចាស់ដីត្រូវបញ្ជាក់ថា ការកាន់កាប់នោះគឺ ៖ ពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។ យ៉ាងនេះក្តីរាល់ការកាន់កាប់ដែលចាប់ផ្តើមបន្ទាប់ពីច្បាប់ភូមិបាលត្រូវបានអនុម័តនៅខែសីហា ឆ្នាំ២០០១ គឺមិនស្របច្បាប់ឡើយ។ អ្នកទិញបន្តបន្ទាប់មានសិទ្ធិកាន់កាប់ដូចភោគីដើមប្រសិនបើពួកគេអាចបង្ហាញឯកសារបញ្ជាក់ពីការកាន់កាប់មុនពេលច្បាប់នេះចូលជាធរមាន។ សិទ្ធិកាន់កាប់ស្របច្បាប់មិនរាប់បញ្ចូលដីសាធារណៈរដ្ឋឡើយ។ ប្រសិនបើការកាន់កាប់បំពេញតាមលក្ខខណ្ឌខាងលើ ម្ចាស់ដីមានសិទ្ធិស្នើសុំប្លង់រឹង។

ការមានប្លង់រឹងជាវិធីតែមួយគត់ដែលម្ចាស់ដីអាចទទួលបានសិទ្ធិជាកម្មសិទ្ធិលើអចលនវត្ថុនោះ។ ដីដែលមានប្លង់រឹងត្រូវបានចុះបញ្ជីនៅថ្នាក់ជាតិ តាមរយៈយន្តការចុះបញ្ជីមួយក្នុងចំណោមយន្តការបី។ ការទទួលស្គាល់ជាផ្លូវការលើកម្មសិទ្ធិជាប្រការសំខាន់ ព្រោះវាអាចកាត់បន្ថយហានិភ័យជម្លោះដីធ្លី និងការពារម្ចាស់ដីពីការបាត់បង់អចលនវត្ថុរបស់ខ្លួន ហើយឯកសារនេះក៏អាចយកទៅប្រើក្នុងតុលាការជាភស្តុតាងក្នុងពេលមានជម្លោះផងដែរ។ ក្រៅពីនេះឯកសារប័ណ្ណកម្មសិទ្ធិដីធ្លីផ្តល់ឲ្យម្ចាស់ដី នូវលទ្ធភាពទទួលបានមូលធនតាមរយៈការដាក់ធានា សម្រាប់កម្ចីប្រាក់ពី

ធនាគារ។ សេចក្តីព្រួយបារម្ភ លើបញ្ហាទាំងនេះតែងតែត្រូវបានលើកឡើង ជាពិសេសបន្ទាប់ពីករណីបឹងកក់ និងកោះពេជ្រ ដែលក្នុងករណីទាំងពីរនេះប្រជាជនដែលមានសិទ្ធិស្របច្បាប់លើដីមិនទទួលបានឱកាសវាយតម្លៃលើ សិទ្ធិកាន់កាប់របស់ពួកគេ មុននឹងដីរបស់ពួកគេត្រូវបានដកហូត។ គួរកត់សម្គាល់ផងដែរថា ប្រជាជនដែលមិនមានសិទ្ធិជាម្ចាស់កម្មសិទ្ធិករលើដីធ្លី អាចជាអ្នកតាំងទីលំនៅដោយមិនស្របច្បាប់សម្រាប់ហេតុផលជាច្រើន បើទោះជាពួកគេជឿថា ពួកគេមានកម្មសិទ្ធិឬការកាន់កាប់ស្របច្បាប់ក៏ដោយ។

បញ្ហាដីធ្លីដែលកើតឡើង ភាគច្រើនបណ្តាលមកពីដីនោះមិនទាន់បានបញ្ជាក់ពីកម្មសិទ្ធិដែលច្បាប់ទទួលស្គាល់ មានន័យថាដីធ្លីមិនទាន់បានចុះបញ្ជីត្រឹមត្រូវ។ មូលហេតុដែលដីមិនទាន់បានចុះបញ្ជីនោះហើយ ដែលនាំឲ្យបញ្ហាវិវាទកើតឡើងជាបន្តបន្ទាប់។

### ២.២.៣. ការចូលកាន់កាន់ដីមិនស្របច្បាប់

ច្បាប់ភូមិបាលឆ្នាំ២០០១ បានកំណត់យ៉ាងច្បាស់អំពីការចូលកាន់កាប់ជាភោគៈ។ ករណីទី១ បើការកាន់កាប់គិតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ អាចត្រូវបានទទួលស្គាល់ថា ជាការកាន់កាប់ដីស្របច្បាប់នាពេលអនាគត ប្រសិនបើការកាន់កាប់ដីនោះមិនទាន់គ្រប់៥ឆ្នាំ ហើយបានបន្តការកាន់កាប់រហូតគ្រប់៥ឆ្នាំដោយគ្មានការតវ៉ា។[30] ករណីទី២ សម្រាប់អ្នកចូលកាន់កាប់ចាប់ពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ មិនអាចចាត់ទុកថាជាការកាន់កាប់ស្របច្បាប់ឡើយ។[31] ដោយឡែកចំពោះការកាន់កាប់ដីសាធារណៈរបស់រដ្ឋ ទោះជាចាប់តាំងពីពេលណាក៏ដោយ អ្នកកាន់កាប់នោះ "គ្មានសិទ្ធិទាមទារសំណងសម្រាប់លើការងារ និងការកែលម្អដែលខ្លួនបានធ្វើនៅលើអចលនវត្ថុ[ដី]នោះឡើយ។"[32]

[30] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៣១។
[31] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា២៩។
[32] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៤៣។

សារាចរលេខ០២ ដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់បានចែងថា ការចូលទៅកាន់កាប់ដោយជនក្រីក្រនិងជនងាយរងគ្រោះ ដើម្បីដោះស្រាយសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃ ដោយសារកំណើនប្រជាជនការរំសាយកងទ័ព ការបាត់បង់ដីដោយសារគ្រោះធម្មជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពអាណាធិបតេយ្យក្នុងការទន្រ្ទានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ នាពេលបច្ចុប្បន្នបានផ្តល់ឱកាសដល់ជនដែលប្រមូលដីទុកលក់ និងជនមានអំណាចមួយចំនួនក្នុងការចាប់យកដីរដ្ឋ ដោយខុសច្បាប់តាមមធ្យោបាយនានា។ ដើម្បីដោះស្រាយបញ្ហានេះសារាចរលេខ ០២ បានធ្វើការកំណត់។

ជាទូទៅអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ជាពិសេសអ្នកប្រមូលដីទុកលក់ គឺពុំមានសិទ្ធិក្នុងការទាមទាមសំណាងឡើយ។[33] អ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ដែលជាគ្រួសារក្រីក្រគ្មានដីឬខ្វះដីនិងជាជនងាយរងគ្រោះពុំមានសិទ្ធិក្នុងការទាមទារសំណងឡើយ ប៉ុន្តែពួកគេអាចទទួលបាននូវការយកចិត្តទុកដាក់ ជាពិសេសដើម្បីទទួលបាននូវចំណែកដី សម្រាប់ប្រកបរបរចិញ្ចឹមជីវិត។[34] ចំពោះដីឯកជនរបស់រដ្ឋ រដ្ឋអាចជាកម្មសិទ្ធិនៃការលក់ ការជួល ការធ្វើប្រទានកម្ម ការផ្តល់សិទ្ធិភោគៈ (សិទ្ធិក្នុងការប្រើប្រាស់ និងអាស្រ័យផលពីដីនោះអស់មួយជីវិត)។ សម្បទានដីសង្គមកិច្ចនិងសម្បទានដីសេដ្ឋកិច្ច ឬការអនុញ្ញាតឲ្យប្រើប្រាស់ក្នុងទម្រង់ ផ្សេងៗទៀតតាមនីតិវិធីជាធរមាន។ ការស្រេចអំពីជម្រើសជាក់លាក់ណាមួយត្រូវធ្វើឡើងផ្អែកលើការសម្របសម្រួលរវាងអាជ្ញាធរដែនដីអាជ្ញាធរកាន់កាប់ដីរដ្ឋនិងបុគ្គលដែលកាន់កាប់ដីឬតវ៉ាអំពីដីនោះនិងផ្អែកលើផែនការប្រើប្រាស់ដី។[35]

### ២.២.៤.ការផ្តល់ដីសម្បទានដីសេដ្ឋកិច្ច

សម្បទានដីធ្លី គឺជាការផ្តល់សិទ្ធិកាន់កាប់លើទីតាំងដីណាមួយសម្រាប់គោលបំណងជាក់

[33] សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, លេខ០២សរ, សារាចរ០២,២៦ កុម្ភៈ ២០០៧,៦.១(តទៅហៅថា សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់)។

[34] សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, ចំណុច៦.២។

[35] សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់,ចំណុច៦.២។

លាក់។ នៅកម្ពុជាសម្បទានដី ត្រូវបានផ្តល់ឲ្យក្នុងមុខងារផ្សេងៗដូចជា កសិអាជីវកម្ម និងការបែងចែកដីធ្លីឡើងវិញដល់ប្រជាជនដែលគ្មានដីធ្លីនិងខ្វះខាតដី។[36] អ្នករាយការណ៍ពិសេសស្តីពីបញ្ហា សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានកត់សម្គាល់ឃើញថាសម្បទាន គឺជាប្រភពដ៏ចម្បងនៃជម្លោះដីធ្លីនៅពាសពេញប្រទេសកម្ពុជា ដោយសារតែជម្លោះនេះទៀតសោតកើតមានឡើងរវាងក្រុមហ៊ុនឯកជន ដែលទទួលបានសម្បទានលើដីដែលគ្រប់គ្រងដោយអ្នកស្រុក។[37]

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ អង្គការជាតិ អង្គការអន្តរជាតិ ស្ថាប័នអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ បានបង្ហាញក្តីបារម្ភជាច្រើនពីផលប៉ះពាល់នៃដីសម្បទានសេដ្ឋកិច្ចលើសហគមន៍ និងបរិស្ថាន។ ជាញឹកញាប់ប្រព័ន្ធផ្សព្វផ្សាយជាតិនិងអន្តរជាតិបានរាយការណ៍ពីករណីដែលអ្នកភូមិបាត់បង់ដីដោយសារក្រុមហ៊ុនសម្បទាន។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានរាយការណ៍ថាសហគមន៍ដែលរស់នៅលើដីដែលត្រូវបានធ្វើសម្បទានតែងតែប្រឈមនឹងការបណ្តេញចេញដោយបង្ខំការតាំងទីលំនៅថ្មីដោយបង្ខំឬការផ្លាស់ទីលំនៅ ដោយមិនមានការរៀបចំត្រឹមត្រូវ។[38] ហេតុការណ៍នេះអាចបង្កើនភាពក្រីក្រដោយសារកង្វះលទ្ធភាពបង្កើតប្រាក់ចំណូល កង្វះលទ្ធភាពទទួលបានទឹកនិងអនាម័យ អគ្គីសនី សេវាសុខភាពនិងការអប់រំ។[39] ក្របខណ្ឌច្បាប់ដើម្បីគ្រប់គ្រងការបណ្តេញចេញដោយបង្ខដោយអង្គភាពឯកជន គឺមិនទាន់មាននៅឡើយនាពេល

[36] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា ៤៨-៥០។

[37] . Subedi, Surya P. *"របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" ក្រុមប្រឹក្សាសិទ្ធិមនុស្សកិច្ចប្រជុំលើកទី២១ខែកញ្ញាឆ្នាំ២០១២,៥៣,* http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A.HRC.21.35_en.pdf (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

[38] Subedi, Surya P. ២០១២. *"របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា"* ក្រុមប្រឹក្សាសិទ្ធិមនុស្សកិច្ចប្រជុំលើកទី២១.១៧កញ្ញាៈ៥៣,ទំព័៩៩. *http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A.HRC.21.35_en.pdf* (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

[39] ដូច៣៦។

បច្ចុប្បន្ននេះ។ ម្យ៉ាងវិញទៀតសម្បទានដីសេដ្ឋកិច្ចបានបង្កឲ្យមានការកាប់បំផ្លាញព្រៃឈើដោយសារតែផ្ទៃដីព្រៃដ៏ធំៗត្រូវបានកាប់ឆ្ការសម្រាប់ធ្វើចម្ការ។[40]

បញ្ហាកង្វល់មួយផ្សេងទៀត ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលគឺការកាន់កាប់ដីធ្លីកាន់តែច្រើនដោយបុគ្គលមួយចំនួនតូចកំពុងធ្វើឲ្យមានកំណើនការបែងចែកដីធ្លីនៅកម្ពុជា ដោយគ្មានសមភាព។ ភាពគ្មានដីធ្លីកើនឡើងដល់២០%ហើយគ្រួសារ៤០%មានដីកសិកម្មតិចជាង០,៥ហិចតាជាលក្ខខណ្ឌទាបំផុតក្នុងការធ្វើកសិកម្មចិញ្ចឹមជីវិត។[41] ក្រៅពីនេះអង្គការសហប្រជាជាតិបានរាយការណ៍បន្ថែមថាការរឹតបន្តឹងលើទំហំនិងកម្មសិទ្ធិនៃសម្បទានដីសេដ្ឋកិច្ចមិនទាន់ត្រូវបានអនុវត្តឲ្យបានត្រឹមត្រូវនៅឡើយទេ។ បុគ្គលមួយចំនួនកាន់កាប់ដីហួសពីទំហំកំណត់ចំនួន១០,០០០ហិកតាជាអតិបរមា។[42] អង្គការសហប្រជាជាតិបានរាយការណ៍ថាសម្បទានដីសេដ្ឋកិច្ចជាច្រើនត្រូវបានផ្តល់ឲ្យក្នុងព្រៃដែលត្រូវបានបម្លែងជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកសារឡើងវិញ។ យោងតាមច្បាប់ភូមិបាល ដីសាធារណៈរបស់រដ្ឋអាចត្រូវបានបែងចែកឡើងវិញប្រសិនបើវាបាត់បង់ប្រយោជន៍សាធារណៈ។[43] ក្រៅពីនេះមានសម្បទានដីសេដ្ឋកិច្ចជាច្រើនដែលស្ថិតនៅក្នុងតំបន់ការពារដែលត្រូវបានផ្តល់ឲ្យទៅក្រុមហ៊ុនបន្ទាប់ពីដីនោះបានឆ្លងកាត់ការបម្លែងជា 'តំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព'។[44]

នៅខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានចេញបទបញ្ជាលេខ០១ បប ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ដែលកំណត់ផ្អាកការផ្តល់

[40] ដូច៣៦។

[41] Alfons Üllenberg. ២០០៩. "វិនិយោគផ្ទាល់ពីបរទេសលើវិស័យដីធ្លីនៅកម្ពុជា". អង្គការ GTZ. http://www2.gtz.de/dokumente/bib-2010/gtz2010-0061en-foreign-direct-investment-cambodia.pdf (*ទស្សនាចុងក្រោយនៅខែមេសា ២០១៩*)។

[42] អ្នកតំណាងពិសេសរបស់អគ្គលេខាធិការសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា. ២០០៧. "*ដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា៖ ទស្សនៈសិទ្ធមនុស្ស*",អង្គការសហប្រជាជាតិ.ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សនៅប្រទេសកម្ពុជា. *http://cambodia.ohchr.org/WebDOCs/DocReports/2-Thematic-Reports/Thematic_CMB12062007E.pdf(Last*(ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

[43] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា ១៦ ។

[44] Surbedi,២០១២,ទំព័រ១៤។

សម្បទានដីសេដ្ឋកិច្ចថ្មីនិងការពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់។[45] បទបញ្ជានេះមិនអនុវត្តទៅលើសម្បទានដីសេដ្ឋកិច្ចដែលកំពុងឆ្លងកាត់ការអនុម័តមុនខែឧសភា ឆ្នាំ២០១២ នោះទេ។ ជាលទ្ធផលសម្បទានដីសេដ្ឋកិច្ចយ៉ាងហោច៣៣កន្លែងត្រូវបានផ្តល់ឲ្យបន្ទាប់ការចេញបទបញ្ជាលេខ០១។[46] នៅខែតុលា ឆ្នាំ២០១៤ ក្រសួងបរិស្ថានបានប្រកាសថាសម្បទានដីសេដ្ឋកិច្ចទាំងនេះនឹងទទួលបានការជួលមិនលើសពី៥០ឆ្នាំឡើយ។[47]

យោងតាមបទបញ្ជាលេខ០១សម្បទានដីសេដ្ឋកិច្ចដែលមិនអនុលោមតាមច្បាប់នេះនឹងត្រូវលុបចោលកិច្ចសន្យា។[48] ជាជម្រើសសម្បទានដីសេដ្ឋកិច្ចដែលមិនគោរពច្បាប់អាចនឹងកាត់បន្ថយផ្ទៃដីព្រមទាំងកាត់បន្ថយរយៈពេលជួល។ កាលពីខែកក្កដា ឆ្នាំ២០១៥ ក្រសួង បរិស្ថានបានប្រកាសថាក្នុងចំណោមសម្បទានដីសេដ្ឋកិច្ច១៦កន្លែងស្ថិតក្រោមការពិនិត្យឡើងវិញសម្បទានដីសេដ្ឋកិច្ចណាដែលមានរយៈពេលជួលលើសពី៧០ឆ្នាំ ត្រូវបានកាត់បន្ថយរយៈពេលជួលមកត្រឹម៥០ឆ្នាំ។[49]

---

[45] អ៊ឹម ឈុនលឹម. ២០១២. "*សុន្ទរកថារបស់ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ". កិច្ចប្រជុំលើកទី ១៩ របស់គណៈកម្មាធិការសម្របសម្រួលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ទីក្រុងភ្នំពេញ ២៦ កញ្ញា ២០១២. ចូលអាន មិថុនា ឆ្នាំ ២០១៥.* http://www.cdc-crdb.gov.kh/cdc/gdcc/nineteenth/agenda5_gov_en.htm (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩) *។*

[46] ដូច៤៥។

[47] Billy Otter. 2014. *«ប្រតិកម្មចម្រុះបន្ទាប់ពីការដកហូតដីសម្បទាន". កាសែត Khmer Times. 3 តុលា ២០១៤.* *www.khmertimeskh.com/news/4964/reactions-mixed-after-land-concessions-revoked/* (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

[48] រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា. ២០១២. "*បទបញ្ជា ០១ បប ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច (ELC)" ។*

[49] តាំង វីដា. ២០១៥. "*រដ្ឋាភិបាលកាត់បន្ថយអាយុរបស់សម្បទានដីសេដ្ឋកិច្ច". កាសែត ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយ ២៩ កក្កដា ២០១៥.* *http://www.phnompenhpost.com/national/lifespan-elcs-slashed-govt* (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចាប់ផ្តើមធ្វើរបាយការណ៍អំពីការកាត់បន្ថយ ផ្ទៃដីដែលកាត់ចេញពីសម្បទានដីសេដ្ឋកិច្ចនៅខែឧសភា ឆ្នាំ២០១៣[50] ប៉ុន្តែគណៈកម្មាការដើម្បីវាយតម្លៃសម្បទានដីសេដ្ឋកិច្ចត្រូវបានបង្កើតនៅខែសីហា ឆ្នាំ២០១៤។[51] សម្បទានដីសេដ្ឋកិច្ចជាច្រើនត្រូវបានលុបចោលឬត្រូវបានកាត់បន្ថយទំហំដី។ ទោះបីជាប្រភពរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថាទំហំផ្ទៃដីដែលបានកាត់ចេញពីសម្បទានដីសេដ្ឋកិច្ច ក៏ទិន្នន័យអំពីការអភិវឌ្ឍពុំមានព័ត៌មានអំពីបញ្ជីជាផ្លូវការឬរបាយការណ៍លម្អិតណាមួយ អំពីសម្បទានដីសេដ្ឋកិច្ចដែលបានកាត់បន្ថយឬលុបចោលក្រោមបទបញ្ជា០១។ របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល មួយដែលបានចេញផ្សាយនៅខែកក្កដា ឆ្នាំ២០១៥ បានរកឃើញថាការពិនិត្យឡើងវិញនិងការលុបចោលសម្បទានដីសេដ្ឋកិច្ច គ្រាន់តែផ្តោតលើសម្បទានដីសេដ្ឋកិច្ចតែប៉ុណ្ណោះ ប៉ុន្តែជៀសវាងសម្បទានដីសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងជម្លោះដីធ្លី និងសម្បទានណាដែលមានទំហំលើសពីទំហំកំណត់ខាងផ្លូវច្បាប់។[52]

រូប៩៖ ចំនួនសម្បទានដីសេដ្ឋកិច្ច




[50] តាំង រីដា. ២០១៥. "*រដ្ឋាភិបាលកាត់បន្ថយអាយុរបស់សម្បទានដីសេដ្ឋកិច្ច". កាសែត ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយ ២៩ កក្កដា ២០១៥.* http://www.phnompenhpost.com/national/lifespan-elcs-slashed-govt (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

[51] Grimsditch, Mark និង Laura Schoenberger (២០១៥). *"សកម្មភាពថ្មី និងគោលនយោបាយចាស់៖ ការអនុវត្ត និងផលប៉ះពាល់នៃបទបញ្ជា០១".វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា៣៩.* *http://www.ngoforum.org.kh/NewActionsandExistingPoliciesImplementationandImpactsofDirective01_Eng.pdf* *ដោយលើកឡើងពីសេចក្តីសម្រេចលេខ ១២៥ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤.* [សេចក្តីសង្ខេបនៃការស្រាវជ្រាវជាភាសារខ្មែរ៖ http://bit.ly/1hkoFvB] (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

[52] សមាគម អាដហុក. *«ដីរបស់នរណា? របាយការណ៍ស្តីពីស្ថានភាពសិទ្ធិដីធ្លីនៅក្នុងប្រទេសកម្ពុជា៖ ឆ្នាំ២០១៤ និងដើមឆ្នាំ២០១៥»* http://www.adhoc-cambodia.org/wp-content/uploads/2015/07/20152107_Land-Report_FINAL.pdf (ទស្សនាចុងក្រោយនៅ ខែមេសា ២០១៩)។

ទំហំដីកាត់ចេញពីសម្បទានដីសេដ្ឋកិច្ចក្រោមការអនុវត្តបទបញ្ជា០១ (គិតជាហិកតា)លើស ពីនេះទៅទៀតបទបញ្ជា០១ អំពាវនាវឲ្យមានការប្រកាន់ភ្ជាប់គោលនយោបាយស្បែកខ្លា ដែលបាន ចែងថាសម្បទានដីសេដ្ឋកិច្ចដែលកំពុងឆ្លងកាត់ការអនុម័តមុនខែឧសភា ឆ្នាំ២០១២គួរតែកំណត់ឲ្យ ជៀសវាងការទន្ទ្រាននៅលើដីដែលមានការកាន់កាប់ និងដីដែលមានការដាំដុះរួចហើយប្រកាសរួម មួយដែលបានចេញផ្សាយនៅឆ្នាំ២០១៤ទាមទារឲ្យសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់គោរព តាមគោលនយោបាយនេះ។ ប៉ុន្តែរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលមួយទៀត ដែល ចេញផ្សាយនៅក្នុងខែមិថុនា ឆ្នាំ២០១៥បានថ្លែងថា ប្រសិទ្ធភាពនៃគោលនយោបាយស្បែកខ្លាលើ កម្មសិទ្ធិដីធ្លីនៅមានកំណត់។[53] ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ រដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ដីដែលបានពីការលុបចោលដីសម្បទានសេដ្ឋកិច្ច ដើម្បីផ្តល់ជាសម្បទានដីសង្គមកិច្ចជូនដល់គ្រួសារក្រីក្រ និងគ្រួសារដែលមានដីធ្លីតិចតួច[54] ទោះជា យ៉ាងណាដីដែល បានដកហូតពីសម្បទានដីសេដ្ឋកិច្ច នឹងត្រូវបានប្រើប្រាស់ដោយវិធីណានោះ គឺពុំ ច្បាស់លាស់នៅឡើយ។[55]

### ករណីការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅតំបន់ភាគឦសាន៖

រាជរដ្ឋាភិបាលផ្តល់ដីសម្រាប់សម្បទានិកសម្រាប់សម្បទានសេដ្ឋកិច្ច បានប៉ះពាល់ទៅដល់ ដីរបស់ជនជាតិដើមភាគតិច ( ចម្ការវិល ដីអារក្ស ជាដើម ) ដែលធ្វើប៉ះពាល់ទៅលើដីធ្លីរបស់

[53] ដូច៥២។

[54] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤,ទំព័រ១៣២។

[55] Grimsditch,២០១៥។

ពួកគាត់។ហើយបានបំផាញនូវប្រពៃណីរបស់ជនជាតិដើមភាគតិច ដែលបណ្តាលមកពីសម្បទានសេដ្ឋកិច្ច។[56]

## ជំពូកទី៣

## យន្តការដោះស្រាយ

### ៣.១ .នីតិវិធីទទួលបានប័ណ្ណកម្មសិទ្ធិ

អ្នកកាន់កាប់ដីធ្លីទោះជាស្ថិតក្នុងរូបភាពណាមួយក៏ដោយ ជាម្ចាស់កម្មសិទ្ធិឬជាភោគីក៏ដោយ សុទ្ធតែមានសិទ្ធិសុំប័ណ្ណកាន់កាប់ ដើម្បីទុកជាភស្តុតាងផ្លូវច្បាប់បញ្ជាក់អំពីសិទ្ធិរបស់ខ្លួនលើដីនេះ។ ដោយការកាន់កាប់ដីធ្លីអាចធ្វើឡើងក្នុងរូបភាពពីរហើយប័ណ្ណកាន់កាប់ក៏មានពីរប្រភេទដែរ គឺប័ណ្ណភោគៈនិងប័ណ្ណកម្មសិទ្ធិ។ ដើម្បីទទួលបានប័ណ្ណនេះម្ចាស់ដីត្រូវដាក់ពាក្យសុំទៅការិយាល័យភូមិបាលស្រុក/ខណ្ឌ តាមរយៈមេឃុំ/ចៅសង្កាត់ ដែលដីនោះតាំងនៅ។

នៅក្នុងជំហានដំបូងមេឃុំ/ចៅសង្កាត់ ត្រូវធ្វើការបញ្ជាក់លើចំណុចពីរ ទី១បញ្ជាក់អំពី អត្តសញ្ញាណស្ថានភាពនិងប្រវត្តិដី (កាលបរិច្ឆេទនៃការចូលកាន់កាប់)។ទី២គឺបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់ដី (ឈ្មោះអត្រានុកូលដ្ឋានទីលំនៅជាដើម)។

នៅក្នុងករណីដែលម្ចាស់ដីមានទីលំនៅ នៅឃុំ/សង្កាត់ផ្សេងពីឃុំ/សង្កាត់ ដែលដីតាំងនៅការបញ្ជាក់ត្រូវធ្វើឡើងដោយឃុំ/សង្កាត់ពីរ គឺឃុំ/សង្កាត់ដែលដីតាំងនៅជាអ្នកបញ្ជាក់អំពីអត្តសញ្ញាណនិងស្ថានភាពដីចំណែកឃុំ/សង្កាត់ដែលជាលំនៅរបស់ម្ចាស់ដី គឺជាអ្នកបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់ដី។

---

[56] https://www.rfa.org/khmer/callshow/impact-of-land-concession-03172014223134.html (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

បន្ទាប់ពីបានទទួលការបញ្ជាក់ពីមេឃុំឬចៅសង្កាត់រួចរាល់ហើយ ដំណាក់កាលបន្ទាប់មកទៀតគឺសុំទៅសាលាស្រុក/ខណ្ឌដែលដីតាំងនៅដើម្បីចាត់ចែងឲ្យមន្ត្រីសុរិយោដីស្រុកចុះវាស់វែងកំណត់ព្រំដី។ នៅក្នុងការវាស់វែងនេះម្ចាស់ដី គឺជាអ្នកចង្អុលបង្ហាញអំពីព្រំដីចំណែកមន្ត្រីសុរិយោដីគ្រាន់តែជាអ្នកវាស់ប៉ុណ្ណោះ។ បន្ទាប់ពីបានវាស់វែងហើយមន្ត្រីសុរិយោដីស្រុកនឹងរៀបចំគូសប្លង់ក្បាលដី។

គួរបញ្ជាក់ថានៅក្នុងការកសាងប្លង់សុរិយោដីនេះ សាលាស្រុកត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈដើម្បីទុកឱកាសឲ្យបុគ្គលពាក់ព័ន្ធធ្វើការតវ៉ា។ នៅមុនពេលចុះវាស់វែងក៏មានការជូនដំណឹងជាសាធារណៈ(១៥ថ្ងៃមុនពេលចុះវាស់)។ នៅក្រោយពេលគូសប្លង់សុរិយោដីរួចហើយ ក៏មានការផ្សព្វផ្សាយជាសាធារណៈជាថ្មីម្តងទៀតអំពីប្លង់ដីនិងអត្តសញ្ញាណម្ចាស់ដី។

៣០ថ្ងៃក្រោយការប្រកាសផ្សាយនេះប្រសិនបើគ្មានការតវ៉ាណាមួយទេនោះអាជ្ញាធរស្រុក/ខណ្ឌនឹងបញ្ជូនសំណុំរឿងទៅឲ្យអាជ្ញាធរសុរិយោដីថ្នាក់ខេត្ត/ក្រុង ជាអ្នកពិនិត្យសម្រេចជាចុងក្រោយក្នុងការចេញប័ណ្ណជូនដល់ម្ចាស់សាម៉ីដែលជាអ្នកសុំ។[57]

អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកសិក្សាស្រាវជ្រាវ បានរាយការណ៍ឲ្យដឹងថាដំណើរការនៃការផ្តល់កម្មសិទ្ធិដីធ្លីនៅប្រទេសកម្ពុជា បានបង្កើតឲ្យមានការប្រឈមនឹងការបណ្តេញចេញដោយបង្ខំសម្រាប់ប្រជាជនខ្លះជាពិសេសប្រជាជននៅទីក្រុងនិងនៅតំបន់ដីមានតម្លៃ។[58] ឧទាហរណ៍នៅភូមិទំនប់រាជធានីភ្នំពេញបន្ទាប់ពីការចុះបញ្ជីដីធ្លីឆ្នាំ២០០៩ ក្បាលដីចំនួន៨០%នៅតែមិនទាន់បានទទួលកម្មសិទ្ធិ។[59] យោងទៅតាមអង្គការសហប្រជាជាតិនៅរវាងឆ្នាំ១៩៩០និង ឆ្នាំ២០១២ ប្រជាជនប្រមាណ

---

57 http://km.rfi.fr/land-property-how-to-get-title-deed *(last Visited April 2019)*។

58 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (*ឆ្នាំ២០១៣). "ប្រទេសកម្ពុជា: ដីធ្លីនៅក្នុងជម្លោះ-ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី." bit.ly/1KtPNVy*។*ម៉ាក ហ្គ្រីមឌីជ និង នីក ហែនឌឹសិន (ឆ្នាំ២០១២). "ភាពគ្មានកម្មសិទ្ធិ: សន្តិសុខ និងអសមភាពកម្មលើកម្មសិទ្ធិ* នៅកម្ពុជា." អង្គការស្ពានឆ្លងកាត់ព្រំដែន. http://www.babcambodia.org/untitled/untitled.pdf (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

59 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ឆ្នាំ២០១៣). *"ប្រទេសកម្ពុជា: ដីធ្លីនៅក្នុងជម្លោះ-ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី."* *http://bit.ly/1KtPNVy* (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

ជា១២០,០០០នាក់ នៅរាជធានីភ្នំពេញត្រូវបានបណ្តេញចេញពីដីធ្លីដោយបង្ខំបើទោះបីគ្មានទិន្នន័យផ្លូវការក៏ដោយ។[60] ចំនួនជាក់លាក់នៅពេលបច្ចុប្បន្នមិនត្រូវបានគេដឹងទេ។ ជាមួយគ្នានេះអ្នកសិក្សាស្រាវជ្រាវបាន រាយការណ៍ថាដំណើរការផ្លូវការស្តីពីការផ្តល់កម្មសិទ្ធិបានបង្កជាអសន្តិសុខកម្មសិទ្ធិដីធ្លីដោយធ្វើឲ្យប៉ះពាល់ដល់សិទ្ធិកាន់កាប់ប្លង់ទន់ដែលតែងតែត្រូវបានបដិសេធចោលនៅពេលអចលនវត្ថុមានតម្លៃខ្ពស់។[61] ជាមួយគ្នានេះដែរសេចក្តីព្រួយបារម្ភតែងធ្លាប់ត្រូវបានលើកឡើង ជាពិសេសនៅក្រោយពីករណីបឹងកក់ និងកោះពេជ្រដែលក្នុងនោះ ប្រជាជនដែលកាន់កាប់លើដីស្របច្បាប់ មិនទទួលបានឱកាសវាយតម្លៃលើសិទ្ធិកាន់កាប់របស់ពួកគេ មុននឹងដកហូតដីរបស់ពួកគេទេ។[62] គួរកត់សម្គាល់ផងដែរថាប្រជាជន ដែលមិនមានសិទ្ធិជាម្ចាស់កម្មសិទ្ធិករ ឬ ភោគីលើដីអាចជាអ្នកតាំងទីលំនៅខុសច្បាប់ បើទោះបីជាពួកគេជឿជាក់ថាពួកគេមានកម្មសិទ្ធិឬការកាន់កាប់ស្របច្បាប់ក៏ដោយ។[63]

នៅទីជនបទអ្នកសិក្សាស្រាវជ្រាវរកឃើញថា ដីដែលមិនបានចុះបញ្ជីជាមួយនឹងប្រព័ន្ធចុះបញ្ជីថ្នាក់ជាតិ គឺត្រូវប្រឈមនឹងការផ្តល់ទៅឲ្យក្រុមហ៊ុនឯកជនតាមរយៈសម្បទានដី។[64] បើទោះជាមានការផ្អាកលើការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០១២ ជម្លោះដីធ្លីពាក់ព័ន្ធនឹងអ្នកភូមិនិងម្ចាស់

---

[60] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស. ឆ្នាំ២០១២. *"ការបណ្តេញចេញ និងការតាំងលំនៅជាថ្មី នៅកម្ពុជា៖ "តម្លៃមនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ." អង្គការសហប្រជាជាតិ.* http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study-28_Feb_2012_Eng.pdf (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

[61] ម៉ាក ហ្គ្រីមឌីជ និង នីក ហែនឌីសិន (ឆ្នាំ២០១២). *"ភាពគ្មានកម្មសិទ្ធិ: សន្តិសុខ និងអសមភាពកម្មលើកម្មសិទ្ធិ នៅកម្ពុជា."* អង្គការស្ពានឆ្លងកាត់ព្រំដែន. http://www.babcambodia.org/untitled/untitled.pdf (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

[62] លីនដា លីមស្ត្រម និង ម៉ាក ហ្គ្រីមឌីជ (ឆ្នាំ២០១៣). *"គោលនយោបាយសម្រាប់អ្នកក្រ? ភ្នំពេញ សន្តិសុខកម្មសិទ្ធិ និងសារាចរលេខ០៣." កិច្ចផ្តួចផ្តើមទីក្រុង.* https://www.academia.edu/8476693/Policy_for_the_Poor_Phnom_Penh_Tenure_Security_and_Circular_03

[63] ដូច៥៩។

[64] ដូចខាងដើម។អាលីស ប៊ីបែន និង ពូ សុវច្ចនា (ឆ្នាំ២០១៩). "សន្តិសុខមនុស្ស និងសិទ្ធិដីធ្លី នៅកម្ពុជា." រាជធានីភ្នំពេញ: វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព. http://www.cicp.org.kh/userfiles/file/Publications/Human-Security-executive-summary-eg-2.pdf (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

សម្បទានដីសេដ្ឋកិច្ចនៅតែបន្តរាយការណ៍ក្នុងប្រព័ន្ធផ្សព្វផ្សាយ។[65] ជាមួយគ្នានេះបុគ្គលនិងក្រុមហ៊ុនដែលមានសញ្ជាតិជាខ្មែរប៉ុណ្ណោះទើបអាចមានសិទ្ធិលើដី។ នៅខែមិថុនា ឆ្នាំ២០១៥ អ្នកភូមិវៀតណាម នៅក្នុងឃុំអរិយក្សត្រ ខេត្តកណ្ដាលបានចាកចេញពីផ្ទះសំបែងរបស់ពួកគេ មុនការកំណត់កាលបរិច្ឆេទបណ្ដេញចេញដើម្បីជៀសវាងជម្លោះហិង្សា។[66]

## ៣.២.ការចុះបញ្ជីដីធ្លី

បន្ទាប់ពីអនុក្រឹត្យលេខ៤៦និងលេខ៤៧ ត្រូវបានយល់ព្រមកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធនិងដាច់ដោយដុំបានចាប់ផ្ដើម។ កម្មវិធីនេះបានផ្ដល់ប័ណ្ណកម្មសិទ្ធិចំនួន២.៦លានច្បាប់ និង ៦០០,០០០ច្បាប់ជូនប្រជាពលរដ្ឋតាមលំដាប់លំដោយនៅត្រឹមខែធ្នូ ឆ្នាំ២០១៤។ ជាមួយនឹងការចុះបញ្ជីដីធ្លីនិងការចេញប័ណ្ណកម្មសិទ្ធិនៅក្រោមក្របខណ្ឌនៃបទបញ្ជាលេខ០១ដែលបានចាប់ផ្ដើមនៅខែមិថុនា ឆ្នាំ២០១២ និងនៅត្រឹមខែធ្នូ ឆ្នាំ២០១៤ ប័ណ្ណកម្មសិទ្ធិចំនួន៦១០,០០០ច្បាប់ ត្រូវបានចេញជូនប្រជាពលរដ្ឋ។[67]

រូប៥៖ ទិន្នន័យនៃការចុះបញ្ជីដីធ្លីនៅកម្ពុជា

[65] ម៉ៃ ទិត្យថារ៉ា (ឆ្នាំ២០១៥). *"អ្នកភូមិ៖ ក្រុមហ៊ុនអភិវឌ្ឍសហភាព ដាក់ចេញការគម្រាមបណ្ដេញចេញជាថ្មី."*,ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ២១ ខែមេសា. http://www.phnompenhpost.com/national/udg-issuing-eviction-threats-again-villagers

[66] https://opendevelopmentcambodia.net/km/topics/land-tenure-and-titling/ (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

[67] https://opendevelopmentcambodia.net/km/topics/land-tenure-and-titling/ (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។




យោងតាមក្រាភិច នៃការចុះបញ្ជីដីធ្លីនៅកម្ពុជា( ការចុះបញ្ជីដីធ្លីមានលក្ខណ:ជាប្រព័ន្ធ និង ការចុះបញ្ជីមានលក្ខណ:ដាច់ដោយដុំ) លទ្ធផលទាំងនោះ បានបង្ហាញឲ្យឃើញនៅឆ្នាំ២០១៣ ការចុះបញ្ជីដីធ្លីលក្ខណ:ជាប្រព័ន្ធបាន២.២៤៩.៣៦២ប័ណ្ណ និងការចុះបញ្ជីដាច់ដោយដុំបាន៦០៤.៥៦៩ប័ណ្ណ។[68] ឆ្នាំ២០១៤ការចុះបញ្ជីដីធ្លីលក្ខណ:ជាប្រព័ន្ធបាន២.៦០១.៦៩៩ប័ណ្ណ និងការចុះបញ្ជីដាច់ដោយដុំបាន១.២៧៦ប័ណ្ណ។[69] ឆ្នាំ២០១៥ការចុះបញ្ជីដីធ្លីលក្ខណ:ជាប្រព័ន្ធបាន១២.៤៧៩ប័ណ្ណ និងការចុះបញ្ជីដាច់ដោយដុំបាន១.៦៩៦ប័ណ្ណ។[70] ឆ្នាំ២០១៦ការចុះបញ្ជីដីធ្លីលក្ខណ:ជាប្រព័ន្ធបាន

[68] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៣ និងលើកទិសដៅការងារឆ្នាំ២០១៤របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ២០០៦ដនស/អរប/រប។

[69] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៤ និងលើកទិសដៅការងារឆ្នាំ២០១៥របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ២០០៨ដនស/អរប/រប។

[70] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ២០១៩ដនស/អរប/រប។

៣ ២០២ ៩៥៨ប័ណ្ណ និងការចុះបញ្ជីដាច់ដោយដុំបាន៦១០ ៩៧០ប័ណ្ណ។[71] ឆ្នាំ២០១៧ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធបាន៣ ៦២៦ ១៥៨ប័ណ្ណ និងការចុះបញ្ជីដាច់ដោយដុំបាន៦ ១៣ ២៨២ប័ណ្ណ។[72] ឆ្នាំ២០១៨ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធបាន៤ ៥១១ ៩៤៣ប័ណ្ណ និងការចុះបញ្ជីដាច់ដោយដុំបាន៦១៥ ៨៧៦ប័ណ្ណ។[73]

### ៣.២.១.ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅរាល់ប័ណ្ណកម្មសិទ្ធិលើដីធ្លីនៅទូទាំងប្រទេសត្រូវបាត់បង់ទាំងអស់។ច្បាប់បានកំណត់លុបចោលរាល់របបកម្មសិទ្ធិទាំងអស់ដែលមានមុនឆ្នាំ ១៩៧៩។ ដើម្បីរៀបចំកសាងបញ្ជីដីធ្លីនិងចេញប័ណ្ណកម្មសិទ្ធិដីធ្លីនៅទូទាំងប្រទេសឡើងវិញច្បាប់បានកំណត់បង្កើតនីតិវិធីពិសេសមួយគឺ"ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ"។

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគឺជាការចុះបញ្ជីដីធ្លី ដែលកើតចេញពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដោយមិនចាំបាច់មានការស្នើសុំពីម្ចាស់ដីឡើយ។ រដ្ឋាភិបាលជាអ្នកកំណត់ជ្រើសរើសភូមិឬឃុំណាមួយដែលត្រូវធ្វើការចុះបញ្ជីដីធ្លី។

នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះត្រូវចែកចេញជា៥ដំណាក់កាលសំខាន់ៗ

ដំណាក់កាលទី១ ត្រៀមរៀបចំ នៅក្នុងដំណាក់កាលនេះរដ្ឋាភិបាលនឹងត្រូវធ្វើការប្រកាសកំណត់តំបន់វិនិច្ឆ័យថាតើត្រូវធ្វើការចុះបញ្ជីដីធ្លីនៅក្នុងឃុំណាមួយ។ នៅក្នុងដំណាក់កាលនេះអាជ្ញាធរត្រូវធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋ នៅក្នុងឃុំឲ្យបានជ្រាបអំពីការចុះបញ្ជីដីធ្លីនេះ ដើម្បីឲ្យប្រជាពលរដ្ឋត្រៀមខ្លួនចូលរួមក្នុងដំណើរការនេះ«៧ថ្ងៃ»។

[71] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០០១ដនស/របា។

[72] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០០២ដនស/អរប/នរប/របា។

[73] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០១២ដនស/អរប/នរប/របា។

គណៈកម្មការមួយត្រូវបង្កើតឡើង ដើម្បីជួយដល់ដំណើរការនៃការចុះបញ្ជីមានលក្ខណៈ ជាប្រព័ន្ធ។ គណៈកម្មការនេះមានសមាសភាពដូចតទៅ អភិបាលខេត្ត-ក្រុងជាប្រធាន អភិបាលស្រុក-ខ័ណ្ឌ ជាសមាជិក ប្រធានក្រុមបច្ចេកទេសវាស់វែង ជាសមាជិក មេឃុំ-ចៅសង្កាត់ ឬតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ជាសមាជិក គ្រប់មេភូមិទាំងអស់ នៅក្នុងឃុំ-សង្កាត់ ជាសមាជិកចាស់ព្រឹទ្ធាចារ្យ ២ រូប ដែលស្គាល់ប្រវត្តិដី នៅក្នុងឃុំ ជាសមាជិក។

ដំណាក់កាលទី២ វាស់វែង និងកសាងប្លង់សុរិយោដី ម្ចាស់ដី គឺជាអ្នកកំណត់ព្រំជាមួយអ្នកជិតខាង។ ចំណែកមន្ត្រីបច្ចេកទេសគ្រាន់តែជាអ្នកចុះទៅវាស់វែងទៅតាមព្រំដែលចង្អុលបង្ហាញដោយម្ចាស់ដីតែប៉ុណ្ណោះ។ ដូច្នេះនៅក្នុងដំណាក់កាលនេះការចូលរួមចំណែកពីម្ចាស់ដី មានសារៈសំខាន់ណាស់។ ម្ចាស់ដីក៏ត្រូវត្រៀមនូវឯកសារចាំបាច់មួយចំនួនផងដែរ។ ឯកសារទាំងនេះរួមមាន សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ បណ្តាំមរតក សាលក្រមតុលាការលិខិតទិញ-លក់ជាដើម។ ល ។

ដំណាក់កាលទី៣ ផ្សព្វផ្សាយអាដ្ឋាធរ ត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ដើម្បីឲ្យប្រជាពលរដ្ឋពាក់ព័ន្ធអាចធ្វើការត្រួតពិនិត្យនិងតវ៉ាសុំធ្វើការកែប្រែ ប្រសិនបើមានកន្លែងមិនត្រឹមត្រូវ(៣០ថ្ងៃ)។ គួរបញ្ជាក់ថានៅក្នុងដំណើរការចុះបញ្ជីនេះ ប្រសិនបើកើតមានវិវាទណាមួយដូចជាវិវាទរឿងព្រំដីជាដើមភាគីជម្លោះអាចសុំឲ្យគណៈកម្មការរដ្ឋបាល ជួយដោះស្រាយនិងសម្រុះសម្រួលឲ្យដោយមិនចាំបាច់ប្តឹងផ្តល់គ្នាទៅដល់តុលាការនោះទេ។

ដំណាក់កាលទី៤ យនិងសម្រេចដំណាក់កាលនេះ គឺមានពាក់ព័ន្ធតែជាមួយស្ថាប័នរដ្ឋតែប៉ុណ្ណោះ។ ផុតរយៈពេល៣០ថ្ងៃ ដែលបើកឲ្យមានការតវ៉ាមន្ត្រីមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យទៅលើប្លង់សុរិយោដីនិង បញ្ជីឈ្មោះម្ចាស់ដីដែលត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ដីទាំងឡាយណាដែលមិនជាប់ មានទំនាស់ហើយមិនមែនចូលជាដីរបស់រដ្ឋនឹងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ដែលប្រធានមន្ទីរភូមិបាលខេត្ត-ក្រុងនឹងចុះហត្ថលេខាលើប័ណ្ណកម្មសិទ្ធិស្ថាពរ។

ដំណាក់កាលទី៥ ការចែកប័ណ្ណៈគឺជាដំណាក់កាលចុងក្រោយ។ ក្រោយពីអាជ្ញាធរចុះហត្ថលេខាចេញប័ណ្ណហើយប័ណ្ណទាំងនេះនឹងត្រូវចែកជូនដល់ម្ចាស់ដីវិញ។ ម្ចាស់ដីត្រូវទៅទទួលប័ណ្ណដោយផ្ទាល់ដៃហើយប័ណ្ណនេះ គឺជាប័ណ្ណកម្មសិទ្ធិស្ថាពរ។[74]

**៣.២.២.ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ**

ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ទាំងឡាយណាដែលមិនទាន់មានកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ដំណើរការនៃនីតិវិធីចុះបញ្ជីមានលក្ខណៈដាច់ដោយដុំមាន៥ដំណាក់កាល។

ដំណាក់កាលទី១ អំពីការដាក់ពាក្យស្នើសុំចុះបញ្ជីដីអ្នកកាន់កាប់ដីត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីទៅរដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ តាម រយៈមេឃុំឬចៅសង្កាត់ដែលក្បាលដីនោះស្ថិតនៅ ហើយពាក្យស្នើសុំត្រូវពិនិត្យដោយរដ្ឋ បាលសុរិយោដី ស្រុក ខណ្ឌ។ ពាក្យស្នើសុំត្រូវធ្វើជាពីរច្បាប់និងអាចមានឯកសារណាបផ្សេងៗភ្ជាប់មកជាមួយដូចជាភស្តុតាងទាក់ទងនិងក្បាលដីឬឯកសារសិទ្ធិក្បាលដីដែលស្នើសុំបញ្ជី។

ដំណាក់កាលទី២ អំពីកិច្ចប្រតិបត្តិការបច្ចេកទេសអំពីការងារវាងអភិបាលស្រុក ខណ្ឌត្រូវផ្សព្វផ្សយជាសាធារណៈអំពីការបរិច្ឆេទនៃការ កំណត់ព្រំដីនិងវាស់វែងយ៉ាងហោចណាស់១៥ថ្ងៃមុនកាលបរិច្ឆេទដើម្បីឲ្យបុគ្គលពាក់ព័ន្ធធ្វើការ ត្រួតពិនិត្យ ឬ តវ៉ា។ ការងារនៅការិយាល័យបន្ទាប់ពីក្រុមមន្ត្រីចុះបញ្ជីដីធ្លី ការកំណត់ព្រំដីវាស់វែងក្បាលដី និងធ្វើការវិនិច្ឆ័យទៅលើឯកសារ និងភស្តុតាងផ្សេងៗនិងត្រូវរៀបចំប្លង់សុរិយោដី។

ដំណាក់កាលទី៣ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវផ្សព្វផ្សាយឯកសារនៃការវិនិច្ឆ័យនោះជាសាធារណៈ រយៈពេល៣០ថ្ងៃនៅសាលាស្រុក ខណ្ឌ ដែលមានសមត្ថកិច្ច។ សេចក្តីថតចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយជាសាធារ

[74] អនុក្រឹត្យ,លេខ ៤៨ អន ក្រ.បក,ជំពូកទី៣,ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ,(តទៅហៅថាការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ)។

ណៈផងដែរនៅទីស្នាក់ការឃុំ សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។ ក្នុងករណីមិនមានការជំទាស់ ឬការតវ៉ាក្នុងការតវ៉ារយៈពេលនៃការបិទផ្សាយជាសាធារណៈទិន្នន័យសុក្រឹត្យដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន។

ដំណាក់កាលទី៤ អំពីការសម្រេចលើឯកសារក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ មន្ត្រីជំនាញត្រូវធ្វើរបាយការណ៍ដាក់ ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ពិនិត្យនិងចុះហត្ថលេខាបញ្ជូនសំណុំរឿងទាំងមូលទៅរដ្ឋបាល សុរិយោដីខេត្ត ក្រុង។

ដំណាក់កាលទី៥ ប្រសិនបើឯកសារត្រឹមត្រូវហើយរដ្ឋបាលសុរិយោដី ថ្នាក់ខេត្ត ក្រុងនិងបញ្ជូនសំណុំរឿងទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលដើម្បីធ្វើការចុះបញ្ជីនិងចេញប័ណ្ណកម្មសិទ្ធិជូនដល់ម្ចាស់ដី។[75]

### ៣.២.៣.ការចុះបញ្ជីដីបំពេញបន្ថែម

ដោយពិនិត្យឃើញថា ក្រោយពីបានបញ្ចាប់ការចុះដីធ្លីមានលក្ខណៈជាប្រព័ន្ធតំបន់មួយចំនួនរួចមក នៅមានក្បាលដីខ្លះស្ថិតក្នុងតំបន់កំពុងវិនិច្ឆ័យ ប៉ុន្តែម្ចាស់នៃក្បាលដីទាំងនោះមិនបានមកចូលរួមបំពេញបែបបទដើម្បីទទួលបានសិទ្ធិពេញលេលតាមការកំណត់។ ក្បាលដីទាំងនេះមានស្ថានភាពខុសៗគ្នាមួយចំនួនត្រូវបានកាន់កាប់ត្រឹមត្រូវ ប៉ុន្តែមិនទាន់ត្រូវបានផ្តល់ប័ណ្ណសម្គាល់សិទ្ធិនៅឡើយ។ ទោះក្នុងរកណីណាក៏ការកាន់កាប់ស្របច្បាប់ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនេះត្រូវបានសម្រួលឲ្យចុះចូលក្នុងសៀវភៅគោលការណ៍បញ្ជីដីធ្លី ដើម្បីធានាសិទ្ធិពេញលេញតាមផ្លូវច្បាប់។

ក្នុងការសម្រួលដោះស្រាយបញ្ហាខាង រដ្ឋាភិបាលបានដាក់ចេញគោលកាណ៍ និងនីតិវិធីនៃការចុះបញ្ជីដីបំពេញបន្ថែម។ រាល់ម្ចាស់អចលនវត្ថុបណាដែលមិនបានចុះបញ្ជីដីលក្ខណៈប្រព័ន្ធដោយមានហេតុផលត្រឹមត្រូវ ត្រូវដាក់ពាក់ស្នើសុំពាក្យបញ្ជី មកកាន់ការិយាល័យរៀបចំដែនដី ន

[75] ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, អនុក្រឹត្យស្តីពី ការចុះបញ្ជីដីធ្លីលក្ខណៈមានដាច់ដោយដុំ មាត្រា១៦ .១៨។

គរូបនីយកម្ម សំណង់ និងភូមិបាល ។មេឃុំ ចៅសង្កាត់ត្រូវពិនិត្យលក្ខណ:សមស្របផ្តល់យោបល់ និងបញ្ជូនសំណុំរឿងមកកាន់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ ស្រុក។ បើការិយាល័យជំនាញពិនិត្យឃើងថា ត្រឹមត្រូវ អ្នកជំនាញនិងធ្វើកំណត់ព្រំ វាស់វែង និងក សាងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ដែលបានស្នើសុំ។ ក្រោយពីរៀបចំសំណុំឯក សារគ្រប់គ្រាន់ ត្រូវបិទផ្សាយជាសារធារណៈរយៈពេល៣០ថ្ងៃនៅសាលាឃុំ សង្កាត់។ ករណីមានការ តវ៉ាមន្ទីជំនាញត្រូវធ្វើការពិនិត្យឡើងវីញរាល់អ្វីដែលពាក់ព័ន្ធ ប៉ុន្តែមិនមានការជំទាស់អ្វីនោះទេ ការិយល័ យជំនាញត្រូវបញ្ជូនទៅសាលាខេត្ត ដើម្បីធ្វើការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ករណីដែលសាលា ខេត្ត មិនយកព្រម ឬប្រានឲ្យ ត្រូវបញ្ជាក់ពីមូលហេតុ ឲ្យបានច្បាស់លាស់ដើម្បីឆ្លើយតបទៅកាន់អ្នកស្នើសុំ វិញ និងទុកឯកសារ។[76]

នៅឆ្នាំ២០១២ បន្ទាប់ពីការសម្រេចបទបញ្ជាលេខ០១ បប ស្តីពីវិធានការពង្រឹងនិងបង្កើន ប្រសិទ្ធភាពការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសគាំទ្របទបញ្ជា នេះថាលោកនឹងដាក់ចេញយុទ្ធនាការចុះវាស់វែងដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិដល់ប្រជាជនដែលរស់ នៅលើដីរដ្ឋរួមទាំង ដីព្រៃ ដីសម្បទានសេដ្ឋកិច្ចនិងដីព្រៃសម្បទាន។

ការផ្តល់ប័ណ្ណកម្មសិទ្ធិតាមបទបញ្ជាលេខ ០១ គឺខុសប្លែកពីដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ វាត្រូវ បានបង្កើតឡើងនៅក្រៅក្របខណ្ឌការចុះបញ្ជីដីធ្លីផ្លូវការ និងទទួលបានមូលនិធិជាឯកជនពីនាយក ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ បានបង្ហាញកាលពីខែកក្កដា ឆ្នាំ២០១៤ ថា នាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយប្រើប្រាស់យុវជនស្ម័គ្រចិត្តចុះវាស់វែងនិងចុះបញ្ជីដីធ្លីរហូតដល់ឆ្នាំ

[76]សារាចរណែនាំស្តីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម, លេខ០៦សណន, ០៥ ឧសភា ២០០៦។

២០១៥។[77] ដីចំនួន៣៨០,០០០ក្បាលដីត្រូវបានចុះបញ្ជីនិងផ្តល់ប័ណ្ណកម្មសិទ្ធិ។[78] យ៉ាងនេះក្តីនៅត្រឹមខែធ្នូ ឆ្នាំ២០១៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាយការណ៍ថា ប័ណ្ណកម្មសិទ្ធិជាង ៦១០,០០០ច្បាប់ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ហើយដីចំនួន ៧១០,០០០ក្បាលដីត្រូវបានចុះវាស់វែងនិងដាក់បង្ហាញតាមគំនិតផ្តួចផ្តើមនៃបទបញ្ជាលេខ០១។[79] កម្មវិធីនេះគឺសកម្មបំផុតរហូតដល់ការបោះឆ្នោតឆ្នាំ២០១៣ជាពេលដែលដំណើរការនេះយឺតយ៉ាងខ្លាំង។ ការផ្តល់ប័ណ្ណកម្មសិទ្ធិបន្តធ្វើឡើងវិញនៅខែធ្នូ ឆ្នាំ២០១៣ ហើយកម្មវិធីនេះត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាលកម្ពុជា។

## សេចក្តីសន្និដ្ឋាន

សិទ្ធិទទួលបានការកាន់កាប់ដីធ្លីនៅតែជាបញ្ហានៅឡើយ ក្នុងសង្គមខ្មែរបច្ចុប្បន្ន។ ថ្វីត្បិតតែប្រទេសកម្ពុជាមានការផ្លាស់ប្តូរច្បាប់ភូមិបាល១៩៩២ទៅច្បាប់ភូមិបាលឆ្នាំ២០០១ ក្នុងគោលបំណងសម្រួលឲ្យប្រជាពលរដ្ឋកាន់តែមានភាពងាយស្រួលក្នុងការកាន់កាប់ដីធ្លី ដោយស្របច្បាប់ និងកាត់បន្ថយជម្លោះដីធ្លី ក៏ដោយ ក៏បញ្ហាដីធ្លីនៅតែជាបញ្ហាចម្រូងចម្រាស។ ទំនាស់ដីធ្លីកើតមានស្ទើរគ្រប់ទីកន្លែងដែលបង្កជាឧបសគ្គដល់ការវិនិយោគ។

ជាក់ស្តែងបញ្ហាសិទ្ធិទទួលបានការកាន់កាប់ដីធ្លីនៅកម្ពុជា នៅតែជាបញ្ហាដដែលនិងជាក្តីកង្វល់របស់ប្រជាពលរដ្ឋ។ បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ

---

[77] អូន ភាព (ឆ្នាំ២០១៤). "*និសិត្សស្ម័គ្រចិត្តចូលនិវត្តន៍ពីកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីរបស់រដ្ឋាភិបាល.*" *ឌឹ ខេបូឌា ដេលី. ថ្ងៃទី ២៦ ខែ ធ្នូ.* https://www.cambodiadaily.com/news/student-volunteers-to-be-retired-from- govt-land-title-program-74875/( ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

[78] រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១៥). "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ: ឆ្នាំ២០១៤-ឆ្នាំ២០១៨." http://countryoffice.unfpa.org/cambodia/drive/NSDP2014-2018.pdf, (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

[79] ម៉ាក ហ្ក្រីមឌីជ និង សឹងប៊ីជី (ឆ្នាំ២០១៥) *ស្រង់ព័ត៌មានពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម (ឆ្នាំ២០១៤). "សេចក្តីជូនដំណឹង." ថ្ងៃទី ១៧ ខែធ្នូ.* http://www.mlmupc.gov.kh/mlm/imgs/notification_En_20141118.pdf (ទស្សនាចុងក្រោយនៅខែមេសា ២០១៩)។

ដែលបានចែងថារាល់របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៥មិនត្រូវបានទទួលស្គាល់[80] និងបានលុបមិនឲ្យមានសិទ្ធិភោគ:បន្ទាប់ពីថ្ងៃទី៣១ ខែសីហាឆ្នាំ២០០១។ ប្រជាពលរដ្ឋមួយចំនួនត្រូវបានបាត់បង់សិទ្ធិកាន់កាប់ដីធ្លីដោយសារការកាន់កាប់មិនស្របច្បាប់និងការរំលោភបំពាន ពីសំណាក់បុគ្គលដែលមានឥទ្ធិពលទៅលើប្រជាពលរដ្ឋស្លូតត្រង់។ ទោះបីជារាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ការចុះបញ្ជីដីធ្លី(ការចុះបញ្ជីជាលក្ខណ:ប្រព័ន្ធ និងការចុះបញ្ជីជាលក្ខណ:ដាច់ដោយដុំ) ជូនប្រជាពលរដ្ឋនិងបានដាក់ចេញនូវវិធានការចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋក្តី ដើម្បីកាត់បន្ថយបញ្ហាដីធ្លី។ ប៉ុន្តែបញ្ហាកាន់កាប់ដីធ្លីបានបង្កឲ្យមានជម្លោះដីធ្លីរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ រវាងប្រជាពលរដ្ឋនិងសម្បទានិកជាដើម....។ បញ្ហាសិទ្ធិទទួលបានការកាន់កាប់ដីធ្លីនៅកម្ពុជាមួយចំនួនទៀត គឺបណ្តាលមកពីការចូលកាន់កាប់ដីធ្លីរបស់រដ្ឋដោយខុសច្បាប់តែម្តង(កាន់ទន្ទ្រានចូលកាន់កាប់ជាដើម...) ដោយពួកគាត់មិនបានយល់ដឹងអំពីច្បាប់ភូមិបាលច្បាស់លាស់។

កង្វះខាតការអនុវត្តច្បាប់ជាមូលហេតុមួយនាំឲ្យប្រជាពលរដ្ឋបាត់បង់នូវសិទ្ធិកាន់កាប់ដីធ្លី។ ដែលបង្កឲ្យមានវិវាទដីធ្លីកើតឡើងហើយមិនបានទទួលការដោះស្រាយប្រកបទៅដោយភាពប្រសិទ្ធភាពនិងតម្លាភាពនូវឡើយ។ ជាហេតុធ្វើឲ្យប្រជាពលរដ្ឋមានការតវ៉ាទាមទានូវសិទ្ធិលើកម្មសិទ្ធិដីធ្លី និងជាហេតុផលមួយដែលនាំឲ្យប្រជាពលរដ្ឋប្រឈម និងភាពក្រីក្រ៕

[80] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៧។

## អនុសាសន៍

រដ្ឋាភិបាលគួរធានាលើច្បាប់ដែលមានស្រាប់ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវ និងយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ម៉្យាងវិញទៀតរាជរដ្ឋាភិបាលត្រូវតែពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលលើរឿងដីធ្លី ដោយជៀសវាងបំពានលើការរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលគួរតែធ្វើសកម្មភាពប្រកបទៅដោយ តម្លាភាព គណនេយ្យភាព និង ភាពយុត្តិធម៌។

ការស៊ើបអង្កេត បញ្ហាការកាន់កាប់ដីធ្លី ដោយឯកពជ្យហើយមិនលម្អៀងនិងប្រកបទៅដោយវិជ្ជាជីវៈ។ ធ្វើការដាក់ទោសទៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលណាដែលបានរំលោភបំពាននិងបានបណ្តាញចេញទាំងបង្ខំដោយខុសច្បាប់ និងលុបបំបាត់នូវវប្បធម៌និទណ្ឌភាពចំពោះជនល្មើស

ច្បាប់។ ការគោរពសិទ្ធិមានកម្មសិទ្ធិនិងសិទ្ធិកាន់កាប់យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លីឲ្យបានឆាប់រហ័សសម្រាប់ប្រជាជនទាំងអស់និងលុបចោលការផ្តល់សម្បទានដីសេដ្ឋកិច្ចទាំងឡាយ ដែលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋនិងបំផ្លាញបរិស្ថាន។

ការជូនដំណឹងនិងអប់រំសហគមន៍អំពីសិទ្ធិរបស់ពួកគាត់ព្រមទាំងចងក្រងព័ត៌មាននិងផ្សព្វផ្សាយជាសាធារណៈអំពីដីប្រភេទណាដែលប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ដោយស្របច្បាប់។ ជម្រុញឲ្យមានការផ្សព្វផ្សាយអំពីនីតិវិធីទទួលសិទ្ធិកាន់កាប់ដីធ្លីដោយស្របច្បាប់ដែលបានចែងជាធរមាន៕

# ឯកសារយោង

## ច្បាប់ និងបទដ្ឋានគតិយុត្ត

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០។

ច្បាប់ភូមិបាល ឆ្នាំ ២០០១។

ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២។ការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, *សារាចរ០២។*

ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, *អនុក្រឹត្យស្តីពី ការចុះបញ្ជីដីធ្លីលក្ខណៈមានដាច់ដោយដុំ។*

រដ្ឋធម្មនុញ្ញាកម្ពុជាប្រជាធិបតេយ្យ។

រដ្ឋធម្មនុញ្ញានៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

សារាចរណែនាំស្តីពីគោលការណ៍និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម *លេខ ០៦ ស.ណ.ន.* ចុះថ្ងៃទី០៥ ខែឧសភាឆ្នាំ២០០៦។

អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

ព្រះរាជក្រម, *ន/ស/រកម/០៨០១/១៨,១៣ ៣០ ខែសីហា ឆ្នាំ២០០១។*

របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៣ និងលើកទិសដៅការងារឆ្នាំ២០១៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០០៦ដនស/អរប/រប។

របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៤ និងលើកទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០០៨ដនស/អរប/រប។

របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០១៤ដនស/អរប/រប។

របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០០១ដនស/របា។

របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០០២ដនស/អរប/នរប/របា។

របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ០១២ដនស/អរប/នរប/របា។

# សៀវភៅ និង ឯកសារពាក់ព័ន្ធ


Üllenberg, Alfons. ២០០៩. *វិនិយោគផ្ទាល់ពីបរទេសលើវិស័យដីធ្លីនៅកម្ពុជា.* អង្គការ GTZ. http://www2.gtz.de/dokumente/bib-2010/gtz2010-0061en-foreign-direct-investment-cambodia.pdf

Billy Otter. 2014.*«ប្រតិកម្មចម្រុះបន្ទាប់ពីការដកហូតដីសម្បទាន". កាសែត Khmer imes. 3 តុលា ២០១៤.* www.khmertimeskh.com/news/4964/reactions-mixed-after-land-concessions-revoked/

Grimsditch, Mark និង Laura Schoenberger (២០១៥).*"សកម្មភាពថ្មី និងគោលនយោបាយចាស់៖ ការអនុវត្ត និងផលប៉ះពាល់នៃបទបញ្ជា០១".វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ៖៣៩។* http://www.ngoforum.org.kh/NewActionsandExistingPoliciesImplementationandImpactsofDirective01_Eng.pdf

Grimsditch. ២០១៥។

http://km.rfi.fr/land-property-how-to-get-title-deed

https://opendevelopmentcambodia.net/km/topics/concessions/#4Z6V4Z6b4Z6U4Z+J4

https://opendevelopmentcambodia.net/km/topics/land-tenure-and-titling/

https://vodhotnews.com/2019/06/26/101923/more-100-families-phnom-penh-who-been-displacing-91-soldiers-blasted-protests/

https://www.rfa.org/khmer/callshow/impact-of-land-concession-03172014223134.html

Matthew Rendall, Jose Trembly, និង Patricia Baars, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ,កែសម្រួល(ភ្នំពេញ East –West Management Institute,Inc,2005)។*

Subedi, Surya P. *"របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" ក្រុមប្រឹក្សាសិទ្ធិមនុស្សកិច្ចប្រជុំលើកទី២១ខែកញ្ញាឆ្នាំ២០១២,៥៣។* http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A.HRC.21.35_en.pd.

Subedi, Surya P. ២០១២. *"របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា"ក្រុមប្រឹក្សាសិទ្ធិមនុស្សកិច្ចប្រជុំលើកទី២១.១៧កញ្ញា៖៥៣,ទំព័៤៩។*

http://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session21/A.HRC.21.35_en.pdf

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស. ឆ្នាំ២០១២. "*ការបណ្ដេញចេញ និងការតាំងលំនៅជាថ្មី នៅកម្ពុជា៖ "តម្លៃមនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ."អង្គការសហប្រជាជាតិ។*
http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study28_Feb_2012_Eng.pdf

*ដោយលើកឡើងពីសេចក្ដីសម្រេចលេខ ១២៥ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤. [សេចក្ដីសង្ខេបនៃការស្រាវជ្រាវជាភាសាខ្មែរ៖* http://bit.ly/1hkoFvB] *។*

តាំង វីដា. ២០១៥. *"រដ្ឋាភិបាលកាត់បន្ថយអាយុរបស់សម្បទានដីសេដ្ឋកិច្ច". កាសែតភ្នំពេញប៉ុស្ដិ៍ចេញផ្សាយ២៩កក្កដា២០១៥។។*http://www.phnompenhpost.com/national/lifespan-elcs-slashed-govt

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ. ២០១៤។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ: *ឆ្នាំ២០១៤-ឆ្នាំ២០១៨។*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (*ឆ្នាំ២០១៣). "ប្រទេសកម្ពុជា: ដីធ្លីនៅក្នុងជម្លោះ-ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី." bit.ly/1KtPNVy។ម៉ាក ប្រ៉ូគ្រីមឌីជ និង នីក ហែនឌឺសិន (ឆ្នាំ២០១២). "ភាពគ្មានកម្មសិទ្ធិ: សន្តិសុខ និងអសមភាពកម្មលើកម្មសិទ្ធិ នៅកម្ពុជា." អង្គការស្ពានឆ្លងកាត់ព្រំដែន.*
http://www.babcambodia.org/untitled/untitled.pdf

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ឆ្នាំ២០១៣). *"ប្រទេសកម្ពុជា: ដីធ្លីនៅក្នុងជម្លោះ-ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី."* http://bit.ly/1KtPNVy

ម៉ាក ប្រ៉ូគ្រីមឌីជ និង នីក ហែនឌឺសិន (ឆ្នាំ២០១២). *"ភាពគ្មានកម្មសិទ្ធិ: សន្តិសុខ និងអសមភាពកម្មលើកម្មសិទ្ធិ នៅកម្ពុជា." អង្គការស្ពានឆ្លងកាត់ព្រំដែន។*
http://www.babcambodia.org/untitled/untitled.pdf

ម៉ាក ប្រ៉ូគ្រីមឌីជ និង សឺងប៊ឺជី (ឆ្នាំ២០១៥) *ស្រង់ព័ត៌មានពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម(ឆ្នាំ២០១៤)."សេចក្ដីជូនដំណឹង."ថ្ងៃទី១៧ខែធ្នូ។*
http://www.mlmupc.gov.kh/mlm/imgs/notification_En_20141118.pdf

ម៉ាក ប្រ៉ូគ្រីមឌីជ និង សឺងប៊ឺជី (ឆ្នាំ២០១៥). *"សកម្មភាពថ្មី និងគោលនយោបាយចាស់: ការអនុវត្តនិងផលប៉ះពាល់នៃបទបញ្ជាលេខ០១"វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា*

http://www.ngoforum.org.kh/NewActionsandExistingPoliciesImplementationandImpactsofDirective01_Eng.pdf

ម៉ៃ ទិត្យថារ៉ា (ឆ្នាំ២០១៥). "*អ្នកភូមិ៖ ក្រុមហ៊ុនអភិវឌ្ឍសហភាព ដាក់ចេញការគម្រាមបណ្ដេញចេញជាថ្មី.*" *ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី ២១ ខែមេសា។*http://www.phnompenhpost.com/national/udg-issuing-eviction-threats-again-villagers

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១៥). "*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ: ឆ្នាំ២០១៤-ឆ្នាំ២០១៨.*" http://countryoffice.unfpa.org/cambodia/drive/NSDP2014-2018.pdf

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា. ២០១២. "*បទបញ្ជា ០១ បប ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច (ELC)*" ។

លីនដា លីមស្រ្តម និង ម៉ាក ប្រ្គីមឌីជ (ឆ្នាំ២០១៣). "*គោលនយោបាយសម្រាប់អ្នកក្រ? ភ្នំពេញ សន្តិសុខកម្មសិទ្ធិ និងសរាចរលេខ០៣.*" *កិច្ចផ្តួចផ្តើមទីក្រុង។*
https://www.academia.edu/8476693/Policy_for_the_Poor_Phnom_Penh_Tenure_Security_and_Circular_03

វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល,*ការវិភាគទិន្នន័យស្តីពីករណីវិវាទដីធ្លីនៅកម្ពុជាក្នុងឆ្នាំ២០០៩។*

វេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា៖ *ការវិភាគទិន្និន័យស្តីពីករណីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ២០១០ទំព័រទី៧។*

វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល៖ *ស្តីពីកម្ពុជាព្រឹត្តិប័ត្រប្រចាំត្រីមាស ,ដី និងជីវិត ឆ្នាំទី៣,លេខ ០៨ ខែតុលា /ធ្នូ ២០០៧។*

សមាគម អាដហុក. «*ដីរបស់នរណា? របាយការណ៍ស្តីពីស្ថានភាពសិទ្ធិដីធ្លីនៅក្នុងប្រទេសកម្ពុជា៖ ឆ្នាំ២០១៤ និងដើមឆ្នាំ២។*

សមាគមអាដហុក*ខែ កុម្ភះ ឆ្នាំ២០១៣៖ផ្លូវបត់សិទ្ធិដីធ្លី និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា។*

សម្បទានដីសេដ្ឋកិច្ច សំណុំទិន្នន័យនេះ *ពុំមានព័ត៌មានទាក់ទងនឹងការកាត់បន្ថយថេរវេលានៃកិច្ចសន្យាដែលកើតចេញមកពីដំណើរការវាយតម្លៃសម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ ២០១៥។*

សែន ដេវីឌ (ឆ្នាំ២០១៥). "*សហគមន៍បណ្តែតទឹកចាកចេញមុនថ្ងៃកំណត់.*" *ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២២ ខែមិថុនា.* http://www.phnompenhpost.com/national/floating-community-clears-out-date

អ៊ឹម ឈុនលឹម. ២០១២. "*សុន្ទរកថារបស់ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ". កិច្ចប្រជុំលើកទី ១៩ របស់គណៈកម្មាធិការសម្របសម្រួលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ទី*

ក្រុងភ្នំពេញ ២៦ កញ្ញា ២០១២. ចូលអាន មិថុនា ឆ្នាំ ២០១៥. http://www.cdc-crdb.gov.kh/cdc/gdcc/nineteenth/agenda5_gov_en.htm

អាលីស ប៊ីប៉ែន និង ពូ សុវច្ចនា (ឆ្នាំ២០១៨). "សន្តិសុខមនុស្ស និងសិទ្ធិដីធ្លី នៅកម្ពុជា." រាជធានីភ្នំពេញ: វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព។ http://www.cicp.org.kh/userfiles/file/Publications/Human-Security-executive-summary-eg-2.pdf

អូន ភាព (ឆ្នាំ២០១៨). "និសិត្សស្ម័គ្រចិត្តចូលនិវត្តន៍ពីកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីរបស់រដ្ឋាភិបាល." ឌឹ ខេបូឌា ដេលី. ថ្ងៃទី ២៦ ខែ ធ្នូ. https://www.cambodiadaily.com/news/student-volunteers-to-be-retired-from- govt-land-title-program-74875/

អ្នកតំណាងពិសេសរបស់អគ្គលេខាធិការសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា. ២០០៧. "ដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា៖ ទស្សនៈ សិទ្ធមនុស្ស". អង្គការសហប្រជាជាតិ. ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សនៅប្រទេសកម្ពុជា http://cambodia.ohchr.org/WebDOCs/DocReports/2-Thematic-Reports/Thematic_CMB12062007E.pdf ។